ព្រះរាជាណាចក្រកម្ពុជា

ជាតិ | សាសនា | ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនទីបង្ហាញផ្លូវ ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា

យុទ្ធសាស្ត្រ និង ការសម្របសម្រួលអន្តរស្ថាប័ន

បរិយាកាសធុរកិច្ច និង វិនិយោគ

ធនធានមនុស្ស និងនវានុវត្តន៍

ហេដ្ឋារចនាសម្ព័ន្ធ

កិច្ចសម្រួលពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ | សាសនា | ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនទីបង្ហាញផ្លូវ
# ការអភិវឌ្ឍវិស័យយានយន្ត
# និងអេឡិចត្រូនិកកម្ពុជា

# បុព្វកថា

ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ស្ថិតក្រោមដំបូលនៃសុខសន្តិភាពនិងស្ថិរភាពពេញលេញ រាជរដ្ឋាភិបាលបាននិងកំពុងសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន សម្រាប់ជាតិមាតុភូមិ ជាពិសេសការបន្តរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ដែលជាកត្តាយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេស កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពប្រជាជន ស្របតាមយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ជាមួយផ្លែផ្កាដែលយើងកំពុងទទួលបាន វិបត្តិនៃជំងឺកូវីដ-១៩ ដែលកើតមានឡើងក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ បានបន្ទុចបង្អាក់ដល់ការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងគន្លងអភិវឌ្ឍន៍រយៈពេលមធ្យមនិងវែង ដោយបានជះផលអវិជ្ជមានដល់សសរស្តម្ភសេដ្ឋកិច្ចជាតិ ជាពិសេសវិស័យទេសចរណ៍ដែលជាចន្ទល់កំណើនសេដ្ឋកិច្ចដ៏សំខាន់មួយរបស់កម្ពុជា។ ឆ្លើយតបទៅនឹងវិបត្តិនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការទាន់ពេល ប្រកបដោយស្មារតីបុរេសកម្ម ម្ចាស់ការ ឈរលើគោលការណ៍ជាក់ស្តែងនិយម និងដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋកម្ពុជា ដើម្បីបង្កើតភាពស៊ាំក្នុងសហគមន៍ តាមរយៈការដាក់ចេញនូវវិធានការសុខាភិបាល វិធានការរដ្ឋបាល និងយុទ្ធនាការជាតិចាក់វ៉ាក់សាំង ព្រមទាំងយុទ្ធសាស្ត្រនិងគោលនយោបាយនានា សំដៅការពារអាយុជីវិតនិងសុខភាពប្រជាជន ព្រមទាំងជំរុញការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ។

យ៉ាងណាមិញ ក្រៅពីវិបត្តិនៃជំងឺកូវីដ-១៩ បញ្ហាប្រឈមដទៃទៀត រួមមាន ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ សង្គ្រាមពាណិជ្ជកម្មនិងបច្ចេកវិទ្យា ការប្រែប្រួលអាកាសធាតុ បញ្ហាសម្ពាធអតិផរណាកើតចេញពីវិបត្តិថាមពល ស្បៀងអាហារ និងហិរញ្ញវត្ថុ ដែលជាផលវិបាកនៃការដាក់ទណ្ឌកម្មសេដ្ឋកិច្ចទៅវិញទៅមករបស់ប្រទេសមហាអំណាចពាក់ព័ន្ធនឹងវិបត្តិសង្គ្រាមនៅអ៊ុយក្រែន ក៏បានបង្កឱ្យមានចលាចលទីផ្សារ ភាពមិននឹងនរនៃប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ និងផលរំខាននានាដល់ខ្សែច្រវាក់ផ្គត់ផ្គង់សកលផងដែរ។ ដើម្បីប្រឈមទប់នឹងវិបត្តិទាំងនេះ ព្រមទាំងត្រៀមខ្លួនចាប់យកកាលានុវត្តភាពថ្មីៗ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ឆ្ពោះទៅរកវិស័យដែលមានតម្លៃបន្ថែមខ្ពស់ និងប្រកបដោយភាពធន់នឹងវិបត្តិ សំដៅស្តារនិងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឡើងវិញឱ្យកាន់តែមានភាពរឹងមាំប្រកបដោយចីរភាពនិងបរិយាបន្ន។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានកំណត់វិស័យយានយន្ត និងអេឡិចត្រូនិក ជាវិស័យអាទិភាព ដើម្បីទាក់ទាញការវិនិយោគនិងបង្កើតការងារដែលមានជំនាញនិងប្រាក់ឈ្នួលខ្ពស់ សំដៅចូលរួមចំណែកស្តារនិងពង្រឹងភាពធន់នៃសេដ្ឋកិច្ចកម្ពុជាក្រោយវិបត្តិនៃជំងឺកូវីដ-១៩។ ការកំណត់យកវិស័យទាំងពីរជាវិស័យអាទិភាព គឺធ្វើឡើងស្របតាមការចង្អុលបង្ហាញរបស់ **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** និង**ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣**។ ក្នុងន័យនេះ **"ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា"** ត្រូវបានផ្តួចផ្តើមឡើង ដើម្បីតម្រង់ទិសការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកនៅកម្ពុជា ដោយបានកំណត់ចក្ខុវិស័យរយៈពេលវែង គន្លងអភិវឌ្ឍន៍តាមដំណាក់កាលនីមួយៗ និងវិធានការគន្លឹះដែលនឹងដោះស្រាយបញ្ហាប្រឈមនានារបស់វិនិយោគិន ដោយប្រកាន់យកនូវអភិក្រម

រហ័សរហួននិងបត់បែនក្នុងការអនុវត្ត។ តាមរយៈការដាក់ចេញនូវផែនទីបង្ហាញផ្លូវនេះ កម្ពុជាអាចទាញយកអត្ថប្រយោជន៍ជាអតិបរមាពីកាលានុវត្តភាពបង្កើតដោយនិន្នាការចម្បងៗ ដែលនឹងផ្លាស់ប្ដូរខ្សែច្រវាក់តម្លៃនាពេលខាងមុខ ព្រមទាំងការធ្វើទំនើបកម្មនិងពិពិធកម្មមូលដ្ឋានឧស្សាហកម្ម ទៅរកសកម្មភាពផលិតកម្មថ្មីដែលមានតម្លៃបន្ថែមខ្ពស់ និងបង្កើនជំនាញព្រមទាំងឯកទេសកម្មរបស់កម្លាំងពលកម្មកម្ពុជាផងដែរ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្ដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានដឹកនាំសម្របសម្រួលរៀបចំផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់នេះ ប្រកបដោយគុណភាពនិងប្រសិទ្ធភាព ក្នុងស្មារតីបុរេសកម្ម ទទួលខុសត្រូវ និងសហការខ្ពស់។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលចក្រភពអង់គ្លេស តាមរយៈកម្មវិធីពន្លឿនការគាំទ្រសេដ្ឋកិច្ចក្នុងដំណាក់កាលជំងឺកូវីដ-១៩ ដែលបានផ្ដល់នូវការគាំទ្រនិងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលក្នុងការរៀបចំផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យទាំងពីរនេះឡើង។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះវិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមក្នុងស្មារតីនៃភាពជាដៃគូយ៉ាងជិតស្និទ្ធ ក្នុងការផ្ដល់ធាតុចូលនិងការរួមចំណែកដល់ការតម្រង់ទិសការអភិវឌ្ឍវិស័យទាំងពីរនេះ។

ជាចុងក្រោយ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ផែនទីបង្ហាញផ្លូវនេះ នឹងក្លាយជាមគ្គុទ្ទេសក៍ដ៏សំខាន់សម្រាប់ជំរុញការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក សំដៅរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន។ ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងតួអង្គនានា ចូលរួមអនុវត្ត និងសហការអនុវត្តវិធានការដែលបានដាក់ចេញក្នុងផែនទីបង្ហាញផ្លូវនេះប្រកបដោយឆន្ទៈមោះមុតនិងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានាបាននូវសមិទ្ធផលដ៏ជោគជ័យក្នុងការអភិវឌ្ឍវិស័យទាំងពីរតាមការរំពឹងទុក។

ថ្ងៃ សុក្រ ១រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបាននិងកំពុងរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងសម្រេចបាននូវកិច្ចអភិវឌ្ឍគួរជាទីមោទនៈលើគ្រប់វិស័យ ជាពិសេសក្នុងការពង្រឹងមូលដ្ឋានឧស្សាហកម្ម ដែលជាកត្តាមួយយ៉ាងសំខាន់ជួយជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន។ យ៉ាងណាមិញ ការរីករាលដាលនៃជំងឺកូវីដ-១៩ គួបផ្សំនឹងភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ចសកល បានបន្តជះឥទ្ធិពលអវិជ្ជមានដល់វិស័យសំខាន់ៗដែលជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ហើយដែលតម្រូវឱ្យមានការគិតគូរដាក់ចេញនូវគោលនយោបាយ និង/ឬ វិធានការ ដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធភាព។

ក្នុងបរិការណ៍នេះ ការពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម និងការពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច តាមរយៈការជំរុញការទាក់ទាញសកម្មភាពឧស្សាហកម្មចំគោលដៅនិងមានតម្លៃបន្ថែមខ្ពស់ កាន់តែមានភាពចាំបាច់និងបន្ទាន់ជាងមុន។ ផ្អែកតាមតម្រូវការនេះ **ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា** ត្រូវបានរៀបចំឡើងជាមគ្គុទ្ទេសក៍ជួយតម្រង់ទិសនិងពន្លឿនការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកថាជាវិស័យអាទិភាពចម្បងនិងមានសក្តានុពលខ្ពស់សម្រាប់ការជំរុញកំណើនសេដ្ឋកិច្ច ជាពិសេសនៅក្នុងដំណាក់កាលក្រោយវិបត្តិជំងឺកូវីដ-១៩។

ផែនទីបង្ហាញផ្លូវនេះ មានចក្ខុវិស័យប្រែក្លាយកម្ពុជាទៅជាមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងបង្គុំយានយន្តនិងបរិក្ខារអេឡិចត្រូនិកសម្រាប់ការនាំចេញទៅកាន់ទីផ្សារក្នុងតំបន់និងសកលលោក ដោយចាប់ផ្តើមពីការផលិតគ្រឿងបង្គុំនិងបរិក្ខារដែលមានលក្ខណៈសាមញ្ញ ឈានឆ្ពោះទៅការកសាងប្រព័ន្ធអេកូឡូស៊ីនៃអ្នកផ្គត់ផ្គង់គ្រឿងបង្គុំយានយន្តនិងបរិក្ខារអេឡិចត្រូនិក ដែលប្រើប្រាស់ជំនាញនិងមានតម្លៃបន្ថែមខ្ពស់សម្រាប់រយៈពេលវែង។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ **ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា** បានកំណត់នូវវិធានការគន្លឹះជាអាទិភាពចំនួន ២០ តាមផ្នែកចំនួន ៥ ដែលរួមមាន ១) យុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន, ២) ធនធានមនុស្ស និងនវានុវត្តន៍, ៣) ហេដ្ឋារចនាសម្ព័ន្ធ, ៤) កិច្ចសម្រួលពាណិជ្ជកម្ម, និង ៥) បរិយាកាសធុរកិច្ច និងវិនិយោគ។

ខ្ញុំជឿជាក់យ៉ាងមុតមាំប្រកបដោយសុទិដ្ឋិនិយមថា ផែនទីបង្ហាញផ្លូវនេះនឹងក្លាយជាឯកសារគោលមួយដ៏មានសារៈសំខាន់ ដែលនឹងជួយតម្រង់ទិសការងារនិងការចូលរួមចំណែករបស់ក្រសួង ស្ថាប័ន វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការជំរុញការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកនៅកម្ពុជា។ ទន្ទឹមនេះ ដើម្បីធានាថាបញ្ហារាំងស្ទះនានាត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាពនិងទាន់ពេល ចាំបាច់ត្រូវមានការចូលរួមសហការយ៉ាងជិតស្និទ្ធប្រកបដោយស្មារតីម្ចាស់ការនិងការទទួលខុសត្រូវខ្ពស់ពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។

ជាទីបញ្ចប់ ក្នុងនាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់តំណាងក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់, លេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រុមហ៊ុនទីប្រឹក្សា Boston Consulting Group (BCG) ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំឯកសារនេះឡើង។ ខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលចក្រភពអង់គ្លេស តាមរយៈស្ថានទូតចក្រភពអង់គ្លេសប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ការគាំទ្រសម្រាប់ការអនុវត្តកម្មវិធីពន្លឿនការគាំទ្រសេដ្ឋកិច្ចក្នុងដំណាក់កាលជំងឺកូវីដ-១៩ (Accelerated Covid-19 Economic Support Programme-ACES) ដើម្បីចូលរួមចំណែកក្នុងការជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងនៅក្នុងការអនុវត្តកម្មវិធី ACES ក៏ដូចជាការរៀបចំឯកសារផែនទីបង្ហាញផ្លូវនេះ តាំងពីដើមរហូតបញ្ចប់ជាស្ថាពរ។

ថ្ងៃ សុក្រ ៩កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២ ខែ ធ្នូ ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ជិន ប៊ុនស៊ាន**

# មាតិកា

**បុព្វកថា** ..... I

**អារម្ភកថា** ..... III

**ខ្លឹមសារសង្ខេប** ..... VII

**ជំពូកទី១៖ សេចក្តីផ្តើម** ..... **១**

១.១. ភាពចាំបាច់នៃការរៀបចំផែនទីបង្ហាញផ្លូវ ..... ១

១.២. ឥទ្ធិពលនៃនិន្នាការចម្បងៗលើវិស័យយានយន្ត និងអេឡិចត្រូនិក ..... ២

១.៣. គុណប្រយោជន៍សម្រាប់វិនិយោគិន ..... ៥

**ជំពូកទី២៖ ទិដ្ឋភាពជារួមនៃការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក** ..... **៧**

២.១. បច្ចុប្បន្នភាពនៃវិស័យយានយន្ត ..... ៧

២.២. បច្ចុប្បន្នភាពនៃវិស័យអេឡិចត្រូនិក ..... ១០

២.៣. ឧត្តមភាពប្រកួតប្រជែង ..... ១២

**ជំពូកទី៣៖. ចក្ខុវិស័យ គន្លងអភិវឌ្ឍន៍ និងគោលដៅ** ..... **១៤**

៣.១. ចក្ខុវិស័យ ..... ១៤

៣.២. គន្លងអភិវឌ្ឍន៍ និងគោលដៅនៃវិស័យយានយន្ត ..... ១៤

៣.៣. គន្លងអភិវឌ្ឍន៍ និងគោលដៅនៃវិស័យអេឡិចត្រូនិក ..... ១៩

**ជំពូកទី៤៖ បញ្ហាប្រឈមក្នុងការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក** ..... **២៤**

៤.១. ភាពចាំបាច់ឱ្យមានយុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន ..... ២៤

៤.២. ធនធានមនុស្ស និងនវានុវត្តន៍ ..... ២៦

៤.៣. ហេដ្ឋារចនាសម្ព័ន្ធ ..... ២៧

៤.៤. កិច្ចសម្រួលពាណិជ្ជកម្ម ..... ២៩

៤.៥. បរិយាកាសធុរកិច្ចនិងវិនិយោគ ..... ២៩

**ជំពូកទី៥៖ វិធានការគន្លឹះសម្រាប់អភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក** ..... **៣១**

៥.១. យុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន ..... ៣៣

៥.២. ធនធានមនុស្ស និងនវានុវត្តន៍ ..... ៣៣

៥.៣. ហេដ្ឋារចនាសម្ព័ន្ធ ..... ៣៤

៥.៤. កិច្ចសម្រួលពាណិជ្ជកម្ម ..... ៣៤

៥.៥. បរិយាកាសធុរកិច្ចនិងវិនិយោគ ..... ៣៤

**ជំពូកទី៦÷ យន្តការស្ថាប័នសម្រាប់ការអនុវត្ត និងការតាមដាននិងវាយតម្លៃ**........................**៣៦**
៦.១. ការរៀបចំយន្តការស្ថាប័ន ........................................................................៣៦
៦.២. ការតាមដាននិងវាយតម្លៃ ........................................................................៤០
**ជំពូកទី៧÷ សេចក្តីសន្និដ្ឋាន**........................................................................**៤១**
**បរិសិដ្ឋ** ........................................................................................................**៤២**
បរិសិដ្ឋទី១÷ អង្គភាពព័ន្ធដែលបានចូលរួមពិគ្រោះយោបល់........................................៤២
បរិសិដ្ឋទី២÷ បន្ទាត់ពេលវេលាសម្រាប់ការអនុវត្តផែនការសកម្មភាព..............................៤៣
បរិសិដ្ឋទី៣÷ ផែនការសកម្មភាពសម្រាប់ការអនុវត្តវិធានការ ........................................៤៤
**បញ្ជីពាក្យកាត់** ...............................................................................................**៦៨**
**សេចក្តីថ្លែងអំណរគុណ** ......................................................................................**៦៩**

# ខ្លឹមសារសង្ខេប

**វិស័យយានយន្ត និងអេឡិចត្រូនិក ត្រូវបានចាត់ទុកជាវិស័យអាទិភាពចម្បងមួយសម្រាប់កិច្ចអភិវឌ្ឍនៅកម្ពុជា។** តាមរយៈភាពជាដៃគូជាមួយវិស័យឯកជន វិស័យទាំងពីរមានការលូតលាស់យ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំចុងក្រោយ។ ការនាំចេញគ្រឿងបង្គុំយានយន្តបានកើនឡើងជាងបីដង ពី៦០លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៥ ដល់ ២០០លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៩ ខណៈដែលការនាំចេញបរិក្ខារអេឡិចត្រូនិកបានកើន ២០% ក្នុងមួយឆ្នាំ ពីប្រមាណ ៤០០លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៥ ដល់ប្រមាណ ៩០០លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៩។ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាអភិវឌ្ឍវិស័យទាំងនេះ ដើម្បីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែង ព្រមទាំងប្រែក្លាយឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្ម ទៅជាឧស្សាហកម្មផ្អែកលើជំនាញ និងធ្វើសមាហរណកម្មទៅក្នុងខ្សែច្រវាក់តម្លៃក្នុងតំបន់ ស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។

**សម្រាប់វិស័យយានយន្ត ក្នុងរយៈពេលខ្លីខាងមុខ កម្ពុជានឹងផ្តោតសំខាន់លើកាលានុវត្តភាពដែលមានស្រាប់ ដើម្បីពង្រីកការផលិតគ្រឿងបង្គុំយានយន្តសាមញ្ញបែបអតិពលកម្មសម្រាប់នាំចេញ** (ឧទាហរណ៍ ខ្សែបង្គុំអគ្គិសនី, កៅអី និងគ្រឿងបង្គុំអេឡិចត្រូនិកនិងអគ្គិសនីសាមញ្ញ) ព្រមជាមួយការបង្កើនការតភ្ជាប់បែបប្រតិគមន៍ (backward linkages) សម្រាប់ការដំឡើងទោចក្រយានយន្ត។ **សម្រាប់វិស័យអេឡិចត្រូនិក ក្នុងរយៈពេលខ្លីខាងមុខ កម្ពុជានឹងផ្តោតសំខាន់លើកាលានុវត្តភាពដែលមានស្រាប់ សម្រាប់បង្កើនការផលិតគ្រឿងបង្គុំសាមញ្ញ និងគ្រឿងដំឡើងបន្ទាប់បន្សំ** (ឧទាហរណ៍ ខ្សែកាប និងឧបករណ៍តភ្ជាប់, គ្រឿងបង្គុំបន្ទះសៀគ្វីបោះពុម្ពរួច (Printed Circuit Board))។ តាមរយៈអភិក្រមនេះ កម្ពុជាអាចប្រើប្រាស់ជាអតិបរមានូវឧត្តមភាពប្រកួតប្រជែងនាពេលបច្ចុប្បន្ន ដូចជាកម្លាំងពលកម្មដែលប៉ិនប្រសប់និងមានប្រាក់ឈ្នួលប្រកួត-ប្រជែង, ទីតាំងយុទ្ធសាស្ត្រនៅជិតប្រទេសថៃនិងវៀតណាម ដែលជាមជ្ឈមណ្ឌលផលិតនិងដំឡើងយានយន្ត និងបរិក្ខារអេឡិចត្រូនិកកំពុងមានការអភិវឌ្ឍឆាប់រហ័ស, និងកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានលក្ខណៈអំណោយផលជាមួយទីផ្សារនាំចេញយានយន្ត និងអេឡិចត្រូនិកសំខាន់ៗ។

ចំពោះគោលដៅបន្ទាប់ក្នុងរយៈពេលមធ្យម កម្ពុជានឹងផ្តោតលើការឈានឡើងក្នុងខ្សែច្រវាក់តម្លៃទៅកាន់**ការផលិតគ្រឿងបង្គុំយានយន្តដែលកាន់តែមានភាពស្មុគស្មាញ** ព្រមទាំង**ការរចនានិងការដំឡើងគ្រឿងបង្គុំអេឡិចត្រូនិកដែលមានតម្លៃបន្ថែមខ្ពស់។** ក្នុងរយៈពេលវែង កម្ពុជាមានបំណងប្រែក្លាយជា **មជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងបង្គុំយានយន្ត**ពីកម្រិតទាបដល់កម្រិតមធ្យមសម្រាប់នាំចេញ និងជា**មជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតបរិក្ខារអេឡិចត្រូនិក** ក្នុងខ្សែច្រវាក់តម្លៃទាំងមូល ចាប់តាំងពីការរចនា ការផលិតគ្រឿងបង្គុំ រហូតដល់ការដំឡើងផលិតផលពាក់កណ្តាលសម្រេចនិងសម្រេច។

ដើម្បីសម្រេចចក្ខុវិស័យក្នុងការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក **រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាអនុវត្តផែនការសកម្មភាពអន្តរស្ថាប័ន ដែលមានភាពគ្រប់ជ្រុងជ្រោយសម្រាប់វិស័យទាំងពីរ សំដៅសម្រួលដល់វិនិយោគិនក្នុងការចាប់ផ្តើមប្រតិបត្តិការនៅកម្ពុជា និងបង្កើនភាពប្រកួតប្រជែងលើតម្លៃផលិតកម្ម។** ផែនការសកម្មភាព មានវិធានការចំនួន ២០ តាមផ្នែកចំនួន ៥ ដូចខាងក្រោម÷

- **យុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន÷** វិធានការមានដូចជា ការកំណត់ទីតាំងឬតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដូចជាថៃ និងវៀតណាម
- **ធនធានមនុស្ស និងនវានុវត្តន៍÷** វិធានការមានដូចជា ការអភិវឌ្ឍកម្មវិធីបង្កើនជំនាញក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក ជាមួយវិស័យឯកជន និងការពង្រីកនិងពង្រឹងសេវាផ្គូផ្គងការងារ តាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន
- **ហេដ្ឋារចនាសម្ព័ន្ធ÷** វិធានការមានដូចជា ការពិនិត្យឡើងវិញនូវអត្រាថ្លៃអគ្គិសនី និងភាពជឿទុកចិត្តបាននូវការផ្គត់ផ្គង់ និងការធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដើម្បីកាត់បន្ថយចំណាយភស្តុភារកម្ម
- **កិច្ចសម្រួលពាណិជ្ជកម្ម÷** វិធានការមានដូចជា ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលត្រូវបានផ្តល់សច្ចាប័ន ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការផ្តល់សេវាសាធារណៈ និងការធ្វើសាមញ្ញកម្មបែបបទនាំចេញ នាំចូល
- **បរិយាកាសធុរកិច្ចនិងវិនិយោគ ÷** វិធានការមានដូចជា ការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលផ្តល់ការលើកទឹកចិត្តបន្ថែមដល់ការវិនិយោគ និងការបង្កើតប្រព័ន្ធអេកូឡូស៊ីសម្រាប់អ្នកផ្គត់ផ្គង់ក្នុងស្រុក តាមរយៈវេទិកាផ្គូផ្គង និងកម្មវិធីបង្កើនគុណភាពសម្រាប់ការផ្គត់ផ្គង់។

**រាជរដ្ឋាភិបាលទទួលស្គាល់ថា ភាពជាដៃគូជិតស្និទ្ធជាមួយវិស័យឯកជន គឺជាគន្លឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពនៃវិស័យយានយន្ត និងអេឡិចត្រូនិក។ ក្នុងន័យនេះ រាជរដ្ឋាភិបាលស្វាគមន៍រាល់ការចូលរួមរបស់វិស័យឯកជន ដើម្បីសហការអភិវឌ្ឍវិស័យទាំងនេះ ចាប់តាំងពីការតម្រង់ទិសយុទ្ធសាស្ត្ររួមរហូតដល់ការរៀបចំ និងអនុវត្តផែនការសកម្មភាពនៃវិធានការនីមួយៗ។** ចំពោះជំហានដំបូង រាជរដ្ឋាភិបាលបានបង្កើត "ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក" ដែលមានការចូលរួមពីក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (អ.ប.វ.) សមាគមធុរកិច្ចជាតិ និងអន្តរជាតិ និងវិនិយោគិនពាក់ព័ន្ធក្នុងវិស័យទាំងពីរ ដើម្បីពិភាក្សានិងកំណត់ទិសដៅការអភិវឌ្ឍវិស័យទាំងនេះ និងធ្វើអាទិភាវូបនីយកម្មវិធានការនានា។

**កាលានុវត្តភាពដែលមានស្រាប់របស់វិស័យទាំងពីរ មានទំហំធំធេងសម្រាប់កម្ពុជា** ជាមួយនឹងសក្តានុពលក្នុងការបង្កើនការនាំចេញប្រមាណ ២,១ពាន់លានដុល្លារអាមេរិក និងបង្កើតការងារថ្មីប្រមាណ ២៦.០០០ កន្លែង ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ ដើម្បីសម្រេចចក្ខុវិស័យអភិវឌ្ឍន៍វិស័យយានយន្ត និងអេឡិចត្រូនិកនៅកម្ពុជា ទាមទារឱ្យមានការប្តេជ្ញា និងភាពជាដៃគូយ៉ាងជិតស្និទ្ធរវាងរាជរដ្ឋាភិបាលនិងវិស័យឯកជនក្នុងការអនុវត្តផែនទីបង្ហាញផ្លូវនេះ។

## ជំពូកទី១៖ សេចក្តីផ្តើម

### ១.១. ភាពចាំបាច់នៃការរៀបចំផែនទីបង្ហាញផ្លូវ

ក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយមុនការរីករាលដាលនៃជំងឺកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាមានកំណើនរឹងមាំគួរឱ្យកត់សម្គាល់ ជាមធ្យមក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ។ ទោះជាយ៉ាងនេះក្តី សកម្មភាពសេដ្ឋកិច្ចមានភាពប្រមូលផ្តុំខ្លាំងក្នុងសកម្មភាពនៃវិស័យប្រពៃណីមួយចំនួនដូចជាវិស័យកសិកម្ម, កាត់ដេរសម្លៀកបំពាក់ ផលិតស្បែកជើងនិងកាបូប, ទេសចរណ៍ និងសំណង់។ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ ក៏បានគូសបញ្ជាក់ពីការប្រមូលផ្តុំនៃអនុវិស័យកម្មន្តសាលដែលមានតម្លៃបន្ថែមទាប ហើយតម្រូវឱ្យមានការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្មទៅរកសកម្មភាពផលិតកម្មថ្មីៗដែលមានតម្លៃបន្ថែមខ្ពស់ បង្កើនជំនាញនិងឯកទេសកម្មរបស់កម្លាំងពលកម្មកម្ពុជា។ បន្ថែមលើនេះ វិបត្តិនៃជំងឺកូវីដ-១៩ បានជំរុញឱ្យកម្ពុជាកាន់តែមានភាពចាំបាច់និងបន្ទាន់ ក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងស្វែងរកប្រភពកំណើនថ្មីដើម្បីពន្លឿនការស្តារ និងរក្សាបាននូវភាពធន់នឹងវិបត្តិ ដែលអាចកើតមាននាពេលអនាគត។

បច្ចុប្បន្ន វិស័យយានយន្ត និងអេឡិចត្រូនិក ត្រូវបានចាត់ទុកជាប្រភពកំណើនថ្មី និងជាវិស័យគន្លឹះក្នុងការចូលរួមអភិវឌ្ឍឧស្សាហកម្មកម្ពុជា ដោយវិស័យទាំងពីរនេះមានសក្តានុពលក្នុងការតភ្ជាប់ខ្សែច្រវាក់តម្លៃក្នុងតំបន់និងសកល និងឈានឡើងជាបណ្តើរៗក្នុងខ្សែច្រវាក់តម្លៃដែលឆ្ពោះទៅរកសកម្មភាពឧស្សាហកម្មផ្អែកលើជំនាញ ព្រមទាំងលើកស្ទួយកំណើនសេដ្ឋកិច្ច ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានរៀបចំនិងដាក់ចេញនូវ "ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា" ក្នុងគោលបំណងកំណត់ចក្ខុវិស័យរយៈពេលវែង និងគន្លងអភិវឌ្ឍន៍ច្បាស់លាស់សម្រាប់វិស័យទាំងពីរនេះ ព្រមទាំងដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តវិធានការជាក់លាក់ ដោយមានការចូលរួមពីវិស័យឯកជននិងអង្គពាក់ព័ន្ធ ដើម្បីជំរុញការអភិវឌ្ឍវិស័យទាំងពីរនេះ។

ផែនទីបង្ហាញផ្លូវនេះត្រូវបានរៀបចំឡើងតាមការចង្អុលបង្ហាញរបស់ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥" ដែលជាមគ្គុទ្ទេសក៍ជំរុញការអភិវឌ្ឍន៍វិស័យឧស្សាហកម្មរយៈពេលវែង និងស្របតាម "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣" ដែលជាផែនការស្តារសេដ្ឋកិច្ចពីវិបត្តិនៃជំងឺកូវីដ-១៩។ ផែនទីបង្ហាញផ្លូវនេះ មានគោលបំណងដោះស្រាយបញ្ហាប្រឈមចម្បង និងមានភាពពាក់ព័ន្ធបំផុតនាពេលបច្ចុប្បន្ន ដើម្បីសម្រួលដំណើរការប្រតិបត្តិការអាជីវកម្មរបស់វិស័យឯកជន ក្នុងវិស័យទាំងពីរ ពោលគឺឯកសារនេះពុំមានគោលដៅដោះស្រាយរាល់បញ្ហាទូទៅទាំងអស់នោះឡើយ។

ផែនទីបង្ហាញផ្លូវនេះមានគោលដៅបង្កើនទំហំនាំចេញក្នុងវិស័យយានយន្តប្រមាណ ៥០០លានដុល្លារអាម៉េរិក និងក្នុងវិស័យអេឡិចត្រូនិកប្រមាណ ១,៦ពាន់លានដុល្លារអាម៉េរិក នៅត្រឹមឆ្នាំ២០២៧ និងបង្កើតការងារថ្មីក្នុងវិស័យយានយន្តប្រមាណ ១០.០០០កន្លែង និងក្នុងវិស័យអេឡិចត្រូនិកប្រមាណ ១៦.០០០កន្លែង នៅត្រឹមឆ្នាំ២០២៧។ តាមការរំពឹងទុក កម្មករិនីនឹងចូលរួមចំណែកប្រមាណ ៥០% ទៅ ៦០% ទៅក្នុងការងារដែលនឹងត្រូវបានបង្កើតសម្រាប់វិស័យទាំងពីរ។

ទន្ទឹមនឹងវិបត្តិនៃជំងឺកូវីដ-១៩ វិបត្តិសង្គ្រាមនៅអ៊ុយក្រែនដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ន ក៏បានបង្កឱ្យមានភាពមិនច្បាស់លាស់ជារួមនៃស្ថានភាពសេដ្ឋកិច្ចសកល និងភូមិសាស្ត្រនយោបាយ ក៏ដូចជាការលេចឡើងនូវនិន្នាការសកលថ្មីៗផងដែរ។ ក្នុងបរិបទនេះ តាមរយៈការដាក់ចេញនូវផែនទីបង្ហាញផ្លូវ កម្ពុជាអាចទាញយកអត្ថប្រយោជន៍ជាអតិបរមាពីកាលានុវត្តភាពបង្កើតដោយនិន្នាការចម្បងៗ ដែលនឹងផ្លាស់ប្តូរខ្សែច្រវាក់តម្លៃនាពេលខាងមុខ។ ឯកសារនេះ ជាឯកសាររស់ ដែលមានភាពបត់បែន អាចផ្តល់លទ្ធភាពដល់ក្រសួង ស្ថាប័នពាក់ព័ន្ធដាក់ចេញនូវផែនការសកម្មភាពបន្ថែម ដែលមានការពាក់ព័ន្ធនិងការឆ្លើយតបទៅនឹងការអភិវឌ្ឍវិស័យទាំងពីរនេះ ទៅតាមភាពចាំបាច់និងតម្រូវការជាក់ស្តែង ព្រមទាំងអាចត្រូវបានកែសម្រួលជាបន្តបន្ទាប់ស្របតាមកាលានុវត្តភាពថ្មីៗដើម្បីឆ្លើយតបនឹងនិន្នាការនានាផងដែរ។

## ១.២. ឥទ្ធិពលនៃនិន្នាការចម្បងៗលើវិស័យយានយន្ត និងអេឡិចត្រូនិក

ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកបាននិងកំពុងប្រឈមនឹងនិន្នាការសកលដ៏សំខាន់មួយគឺ **បម្រែបម្រួលខ្សែច្រវាក់ផ្គត់ផ្គង់**។ ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងការរំខានដល់ខ្សែច្រវាក់ផ្គត់ផ្គង់ដែលកើតចេញពីការរីករាលដាលនៃជំងឺកូវីដ-១៩ បានជំរុញឱ្យក្រុមហ៊ុនមួយចំនួនធ្វើពិពិធកម្មមូលដ្ឋានផលិតកម្មរបស់ខ្លួនទៅកាន់ទីតាំងផ្សេងៗ និងបង្កើតខ្សែច្រវាក់ផ្គត់ផ្គង់ដដែលៗ (គ្រឿងបង្គុំដូចគ្នា នៅទីតាំងផ្សេងគ្នា) តាមរយៈអ្នកផ្គត់ផ្គង់ផ្សេងទៀតដែលមានសមត្ថភាពផលិត និងអាចបត់បែនតាមតម្រូវការបាន។ បច្ចុប្បន្ន ក្រុមហ៊ុនជាច្រើន បាននិងកំពុងស្វែងរកទីតាំងបង្កើតរោងចក្រច្រើនកន្លែង ដើម្បីពង្រឹងភាពធន់ ខណៈដែលថ្លៃដើមផលិតកម្មនៅតែជាកត្តាចម្បងមួយក្នុងការសម្រេចចិត្តបណ្តាក់ទុនវិនិយោគ។ បន្ថែមលើនេះ ការបង្កើតរោងចក្រទីពីរ (second manufacturing plant) ឬរោងចក្រដែលមានទីតាំងក្បែរៗគ្នា អាចជួយបំពេញបន្ថែមលើប្រតិបត្តិការដែលមានស្រាប់ កាត់បន្ថយហានិភ័យ និងពង្រឹងនិរន្តរភាពធុរកិច្ច។ ក្រុមហ៊ុនផលិតជាច្រើន បានអនុវត្តវិធីសាស្ត្រនេះដោយជោគជ័យ ដោយប្រើរូបមន្តយុទ្ធសាស្ត្រប្រទេសបូកមួយ។ និន្នាការនេះនឹងផ្តល់កាលានុវត្តភាពដ៏ល្អក្នុងការទាញយកអត្ថប្រយោជន៍ពីយុទ្ធសាស្ត្រប្រទេសបូកមួយ ដោយកម្ពុជាមានទីតាំងយុទ្ធសាស្ត្រស្ថិតចំកណ្តាលតំបន់អាស៊ាន គួបផ្សំនឹងឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា ដែលអាចផ្តល់នូវមូលដ្ឋានសម្រាប់ក្រុមហ៊ុនក្នុងការបង្កើតរោងចក្រទីពីរ។

ក្រៅពីនិន្នាការរួមខាងលើ ផ្នែកខាងក្រោមនឹងរៀបរាប់ពីនិន្នាការដោយឡែកដែលលេចឡើងក្នុងវិស័យនីមួយៗ។

### ១.២.១ វិស័យយានយន្ត

- **ការកើនឡើងនៃយានយន្តអគ្គិសនី៖** ចំណែកនៃការលក់យានយន្តអគ្គិសនីក្នុងទីផ្សារយានយន្ត មានទំនោរកើនឡើងយ៉ាងឆាប់រហ័សក្នុងមួយទសវត្សរ៍ខាងមុខ ដោយរំពឹងថាចំណែកនៃការលក់យានយន្តអគ្គិសនីធៀបនឹងការលក់យានយន្តថ្មីសរុបទូទាំងពិភពលោក នឹងកើនឡើងពី២%ក្នុងឆ្នាំ២០២០ ទៅ១៨%ក្នុងឆ្នាំ២០៣០។ ការកើនឡើងនៃយានយន្តអគ្គិសនី នឹងកែប្រែខ្សែច្រវាក់តម្លៃនិងផ្គត់ផ្គង់យានយន្ត ដោយសារយានយន្តអគ្គិសនីមិនទាមទារឱ្យមានការដំឡើងស្មុគស្មាញ ហើយប្រើគ្រឿងបង្គុំតិច បើប្រៀបធៀបជាមួយយានយន្តដែលប្រើប្រាស់ម៉ាស៊ីនចំហេះក្នុង។ ទីផ្សារសកលថ្មីមួយ ដែលមានតម្លៃចាប់ពី ២៥០ ដល់ ៣០០ពាន់លានដុល្លារអាម៉េរិក សម្រាប់គ្រឿងបង្គុំយានយន្តអគ្គិសនី (ដូចជាអាគុយ និងគ្រឿងបង្គុំម៉ាស៊ីនសម្រាប់យានយន្តអគ្គិសនី) អាចនឹងលេចឡើងក្នុងឆ្នាំ ២០៣០ និងបង្កើតតម្រូវការផ្សេងៗ សម្រាប់ក្រុមហ៊ុនផលិតគ្រឿងបង្គុំយានយន្ត ជាពិសេសផ្នែកគ្រឿងបង្គុំអគ្គិសនី និងអេឡិចត្រូនិក។ ដំណើរការផ្គុំដំឡើងយានយន្តអគ្គិសនីដែលមិនសូវស្មុគស្មាញ ក៏អាចនឹងនាំឱ្យមានការផលិតយានយន្តអគ្គិសនីធុនតូចនិងមានតម្លៃទាប ក្នុងបរិមាណកាន់តែច្រើន ដែលអាចបង្កើនតម្រូវការយានយន្តថ្មីនៅកម្ពុជា និងតំបន់អាស៊ានផងដែរ។ ម៉ូដែលយានយន្តអគ្គិសនីដែលមានតម្លៃទាបដូចជា ម៉ាក Hong Guang Mini កំពុងទទួលបានប្រជាប្រិយភាពយ៉ាងខ្លាំងនៅប្រទេសចិន (យានយន្តអគ្គិសនីថ្មីមួយចំនួនមានតម្លៃត្រឹម៤.៥០០ដុល្លារអាម៉េរិកប៉ុណ្ណោះ) ហើយអាចនឹងមានសក្តានុពលនៅក្នុងតំបន់ផងដែរ ប្រសិនបើមានហេដ្ឋារចនាសម្ព័ន្ធសមស្រប ដើម្បីគាំទ្រដល់ការប្រើប្រាស់យានយន្តអគ្គិសនីឱ្យបានទូលំទូលាយ។
- **ទស្សនទានថ្មីនៃការបន្លាស់ទី៖** ក្រៅពីយានយន្តអគ្គិសនី ក៏មានបច្ចេកវិទ្យាផ្សេងទៀត ដែលកំពុងជះឥទ្ធិពលទៅលើទស្សនទានដែលមានស្រាប់នៃការបន្លាស់ទី និងអាចផ្លាស់ប្តូរទិដ្ឋភាពនៃខ្សែច្រវាក់តម្លៃឧស្សាហកម្មយានយន្ត។ ជាក់ស្តែង ចំនួនរថយន្តស្វ័យប្រវត្តិ (autonomous cars) អាចនឹងមានការកើនឡើងកាន់តែច្រើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ដែលនឹងពន្លឿននិន្នាការឈានទៅកាន់ការប្រើប្រាស់យានយន្តរួមគ្នា ជាពិសេសនៅទីប្រជុំជន។ បច្ចេកវិទ្យាយានយន្តស្វ័យប្រវត្តិ អាចជំរុញការប្រើប្រាស់សក្តានុពលនៃការបន្លាស់ទីរួមគ្នាបានពេញលេញ ដែលធ្វើឱ្យការធ្វើដំណើរកាន់តែមានតម្លៃសមរម្យសម្រាប់អតិថិជន ដោយប្រើប្រាស់យានយន្តស្វ័យប្រវត្តិ (ដូចជា រថយន្តឈ្នួលរ៉ូបូត ដោយសារតែតម្លៃសម្រាប់អ្នកដំណើរម្នាក់ក្នុងរថយន្តឈ្នួលរ៉ូបូត ទាបជាងយ៉ាងហោចណាស់មួយភាគបី បើធៀបនឹងរថយន្តផ្ទាល់ខ្លួន) ព្រមទាំងជួយកាត់បន្ថយផលប៉ះពាល់បរិស្ថានដែលបង្កដោយការធ្វើដំណើរ។

- **ការផ្លាស់ប្តូរនៃចំណង់ចំណូលចិត្តរបស់អតិថិជន÷** ចំណង់ចំណូលចិត្តរបស់អតិថិជនក្នុងវិស័យយានយន្ត នៅតែបន្តមានការវិវត្តជានិច្ច។ និន្នាការសំខាន់ៗ ចំនួន ២ រួមមាន÷ ១- ការផ្តោតសំខាន់កាន់តែខ្លាំង លើសុវត្ថិភាព និង ២- ការយល់ដឹងកាន់តែច្រើនអំពីបញ្ហាបរិស្ថាន ជាពិសេសក្នុងចំណោមអ្នកប្រើប្រាស់វ័យក្មេង ដែលគាំទ្រការផ្លាស់ប្តូរទៅប្រើប្រាស់យានយន្តហាយប្រ៊ីដ (Hybrid) និងយានយន្តអគ្គិសនី។ ថ្វីត្បិតតែនិន្នាការទាំងនេះហាក់ដូចជាមានកំណើនគាំទ្រពីប្រទេសជាច្រើនក៏ពិតមែន ប៉ុន្តែឥទ្ធិពលនៃនិន្នាការទាំងនេះទៅលើឥរិយាបថនៃការទិញដូររបស់អតិថិជន ក៏ដូចជាវិសាលភាពនិងភាពទាក់ទាញនៃទំនោរទាំងនេះនៅកម្ពុជា នៅតែពិបាកក្នុងការព្យាករនៅឡើយ។ ទោះជាយ៉ាងណាក្តី ប្រសិនបើនិន្នាការទាំងនេះទទួលបានប្រជាប្រិយភាពក្នុងប្រទេសកម្ពុជា វានឹងអាចជួយពន្លឿនកម្ពុជាឱ្យចាកចេញពីការប្រើប្រាស់រថយន្តមួយទឹកដ៏ច្រើនលើសលប់នៅក្នុងទីផ្សាររថយន្តក្នុងស្រុក ហើយឆ្ពោះទៅរកកំណើនតម្រូវការរថយន្តថ្មី ដែលគាំទ្រដល់បរិស្ថានបៃតង និងមានសុវត្ថិភាពជាងមុន។
- **ម៉ូដែលផលិតកម្មថ្មី÷** បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ កំពុងបង្កើតឱ្យមានម៉ូដែលផលិតកម្មយានយន្តថ្មី ដែលមានសក្តានុពលបង្អាក់ខ្សែច្រវាក់ផ្គត់ផ្គង់យានយន្តសកល។ ម៉ូដែលផលិតកម្មនេះ រួមមាន "រោងចក្រខ្នាតមីក្រូផលិតយានយន្ត" អាចដំណើរការតាមរយៈការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មកម្រិតខ្ពស់ និងបញ្ញាសិប្បនិម្មិត ដែលអាចទទួលបានប្រាក់ចំណេញ ដោយគ្រាន់តែផលិតរថយន្តបានក្នុងបរិមាណត្រឹម ១.០០០គ្រឿងក្នុងមួយឆ្នាំ បើធៀបនឹងរោងចក្រដំឡើងយានយន្តបែបប្រពៃណី ដែលតម្រូវឱ្យផលិតបានក្នុងបរិមាណច្រើនជាងនេះ ៥០ ទៅ ១០០ ដង។ រោងចក្រខ្នាតមីក្រូទាំងនេះមានលក្ខណៈសមស្របសម្រាប់ស្ថានភាពប្រទេសកម្ពុជាដែលតម្រូវការយានយន្តក្នុងស្រុកបច្ចុប្បន្ននៅមានចំនួនតិចដោយរោងចក្រទាំងនេះអាចកាត់បន្ថយហានិភ័យនិងចំណាយក្នុងការរៀបចំខ្សែច្រវាក់ផលិតកម្ម។ ទោះជាយ៉ាងនេះក្តី ម៉ូដែលផលិតកម្មបែបនេះ មិនទាន់ត្រូវបានអនុវត្តទូលំទូលាយនៅឡើយទេ ហើយដែលអាចនឹងរីកដុះដាលនៅចុងទសវត្សរ៍នេះប៉ុណ្ណោះ តាមរយៈការប្រើប្រាស់បញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យានៃឧស្សាហកម្ម ៤.០ ដទៃទៀត។

### ១.២.២ វិស័យអេឡិចត្រូនិក

- **កំណើនតម្រូវការ÷** វិស័យអេឡិចត្រូនិកនៅតែវិវត្តជាបន្តបន្ទាប់ ស្របជាមួយនឹងការពន្លឿនវេខូបនីយកម្មពិសេសក្នុងបរិការណ៍ជំងឺកូវីដ-១៩។ គួបផ្សំនឹងកំណើនចំនួនប្រជាជនដែលមានកម្រិតជីវភាពមធ្យម តម្រូវការបរិក្ខារអេឡិចត្រូនិកបាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័ស ជាពិសេសនៅក្នុងទីផ្សារដែលកំពុងរីកលូតលាស់ដូចជាអាស៊ាន។ បើយោងតាមស្ថាប័នស្រាវជ្រាវ Euromonitor ទីផ្សារបរិក្ខារអេឡិចត្រូនិកជាសកល ត្រូវបានព្យាករថានឹងឈានដល់ ១,៤ទ្រីលានដុល្លារអាមេរិក នៅឆ្នាំ២០២៥ ហើយអាស៊ានគឺជាទីផ្សារដែលរីកលូតលាស់លឿនបំផុតទី៣ សម្រាប់ឧបករណ៍អេឡិចត្រូនិក ដែល

មានកំណើនជាមធ្យមប្រចាំឆ្នាំ ៦,៥% បន្ទាប់ពីប្រទេសប្រេស៊ីល និងឥណ្ឌា។ ការកើនឡើងនៃតម្រូវការបរិក្ខារអេឡិចត្រូនិកនៅទូទាំងពិភពលោក នឹងកំពុងផ្តល់កាលានុវត្តភាពកាន់តែច្រើនដល់កម្ពុជាក្នុងការចាប់យកចំណែកទីផ្សារនៃផលិតផលផ្សេងទៀតដែលមានកំណើនតម្រូវការខ្ពស់។

- **ការប្រើប្រាស់បច្ចេកវិទ្យាចល័តចុងក្រោយ ដូចជា ៥G ជាដើម៖** ជាមួយនឹងការដាក់ឱ្យដំណើរការបណ្តាញ៥G កម្មវិធីថ្មីៗត្រូវបានរំពឹងថានឹងលេចឡើង។ ជាក់ស្តែង ឧបករណ៍ប្រើប្រាស់បច្ចេកវិទ្យានិម្មិតទិដ្ឋភាព (AR/VR) និងយានយន្តស្វ័យប្រវត្តិ គឺជាផលិតផលកំពុងមានវត្តមានក្នុងទីផ្សាររួចទៅហើយ ដែលជំរុញដោយបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ ដោយសារនិន្នាការទាំងនេះហាក់ដូចជាកំពុងតែមានសន្ទុះជាសកល កម្មវិធីជំនាន់ថ្មីៗជាច្រើនត្រូវបានរំពឹងថានឹងលេចរូបរាងឡើង ប្រកបដោយភាពច្នៃប្រឌិតនៅពេលដែលការពង្រាយបណ្តាញ៥Gកាន់តែរីកដុះដាល។ ខណៈដែលបណ្តាញ៥Gកំពុងត្រូវបានដាក់ឱ្យដំណើរការ វាអាចត្រូវការពេល ២-៣ឆ្នាំ ទៅមុខទៀត ដើម្បីឱ្យការប្រើប្រាស់បណ្តាញ៥G កាន់តែទូលំទូលាយ។ ដោយមើលឃើញពីការចាប់ផ្តើមជាបណ្តើរៗនៃនិន្នាការនេះ កម្ពុជាមានសក្តានុពលក្នុងការចាប់យកទីផ្សារនៃការប្រើប្រាស់បច្ចេកវិទ្យា៥G និងបច្ចេកវិទ្យាជំនាន់ថ្មីដទៃទៀតនាពេលអនាគត។

## ១.៣. គុណប្រយោជន៍សម្រាប់វិនិយោគិន

ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិកនៅកម្ពុជា ផ្តល់គុណប្រយោជន៍ដល់ក្រុមហ៊ុនក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក ដែលមានបំណងវិនិយោគនៅកម្ពុជា ដូចខាងក្រោម៖

- **ការប្តេជ្ញារយៈពេលវែងរបស់រាជរដ្ឋាភិបាលចំពោះវិស័យយានយន្ត និងអេឡិចត្រូនិក៖** ផែនទីបង្ហាញផ្លូវឆ្លុះបញ្ចាំងពីការទទួលស្គាល់របស់រាជរដ្ឋាភិបាលលើវិស័យទាំងពីរនេះ ដែលដើរតួនាទីសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍឧស្សាហកម្មកម្ពុជា។ ក្រុមហ៊ុនក្នុងវិស័យយានយន្តនិងអេឡិចត្រូនិកដែលមានបំណងវិនិយោគនៅកម្ពុជា អាចជឿជាក់លើការប្តេជ្ញារយៈពេលវែងរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តវិធានការនានាដើម្បីដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិន និងសម្រេចបាននូវគន្លងផ្លូវអភិវឌ្ឍន៍ដែលបានកំណត់
- **អភិក្រមផ្តោតលើការចូលរួមរបស់វិនិយោគិនក្នុងការអភិវឌ្ឍវិស័យទាំងពីរ៖** ផ្អែកតាមអភិក្រមនេះ រាជរដ្ឋាភិបាលស្វាគមន៍រាល់មតិយោបល់ពីក្រុមហ៊ុនក្នុងវិស័យយានយន្តនិងអេឡិចត្រូនិកដែលកំពុងមានវត្តមាននៅកម្ពុជា ឬវិនិយោគិនសក្តានុពល អំពីបញ្ហាប្រឈមរបស់ពួកគេ។ លើសពីនេះ រាជរដ្ឋាភិបាលស្វែងរកកិច្ចសហការជាមួយវិនិយោគិនដែលមានស្រាប់និងវិនិយោគិនសក្តានុពល ដើម្បីរៀបចំយុទ្ធសាស្ត្ររួមក្នុងការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិក។ រាជរដ្ឋាភិបាលបានបង្កើត "ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក" ដែលផ្តល់កាលា-

នុវត្តភាពដល់វិនិយោគិន ក្នុងការស្វែងយល់កាន់តែច្បាស់ពីផែនការរបស់រាជរដ្ឋាភិបាល ព្រមទាំងជួយតម្រង់ទិសនិងរៀបចំគោលនយោបាយ សម្រាប់វិស័យទាំងពីរផងដែរ

- **ការធ្វើឱ្យប្រសើរឡើងបរិយាកាសធុរកិច្ច និងវិនិយោគ÷** តាមរយៈការអនុវត្តផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលដែលមានចរិតអន្តរក្រសួង ក្រុមហ៊ុនក្នុងវិស័យយានយន្តនិងអេឡិចត្រូនិកដែលកំពុងវិនិយោគនៅកម្ពុជាអាចរំពឹងថានឹងទទួលបាននូវភាពកាន់តែប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិ-យោគ រួមមានធនធានមនុស្ស និងនវានុវត្តន៍, ហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចសម្រួលពាណិជ្ជកម្ម។ បន្ថែមលើនេះ ការអនុវត្តផែនការនិងវិធានការគោលនយោបាយដែលមានស្រាប់ឱ្យទាន់ពេលវេលា ដូចជាការវិនិយោគលើវិស័យអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ក៏នឹងចូលរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវភាពទាក់ទាញរបស់កម្ពុជាផងដែរ។ វិធានការភាគច្រើនក្នុងផែនទីបង្ហាញផ្លូវនេះ ជាវិធានការថ្មីដែលដាក់ចេញ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលវិនិយោគិនបានលើកឡើងក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាពេលកន្លងមក។

**ជារួម វិធានការទាំងនេះ នឹងបង្កើនភាពងាយស្រួលដល់វិនិយោគិនក្នុងការធ្វើធុរកិច្ច និងបណ្តាក់ទុនវិនិយោគនៅកម្ពុជា ព្រមទាំងបង្កើនភាពប្រកួតប្រជែងលើថ្លៃប្រតិបត្តិការ** (ឧទាហរណ៍ តាមរយៈការបញ្ចុះថ្លៃអគ្គិសនី ថ្លៃដឹកជញ្ជូននិងភស្តុភារកម្ម)។

# ជំពូកទី២÷ ទិដ្ឋភាពរួមនៃការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក

## ២.១. បច្ចុប្បន្នភាពនៃវិស័យយានយន្ត

រូបភាពទី១÷ បច្ចុប្បន្នភាពនៃវិស័យយានយន្តនៅកម្ពុជា




ចំណាំ÷ គំនូសតាងមិនមានមាត្រដ្ឋានទេ។

ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

វិស័យយានយន្តនៅកម្ពុជា មានកំណើនយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការនាំចេញជាមធ្យមប្រចាំឆ្នាំរបស់វិស័យយានយន្តក្នុងអំឡុងឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ មានការកើនឡើងទ្វេដង ធៀបនឹងការនាំចេញនៅឆ្នាំ២០០៩ ដល់ឆ្នាំ២០១២ ដោយសារតែទំហំទុនវិនិយោគពីបរទេសមានការកើនឡើង។ ចន្លោះឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩ កម្ពុជាទទួលបានគម្រោងវិនិយោគថ្មីលើវិស័យយានយន្តជាមធ្យមចំនួន ៤ គម្រោង ក្នុងមួយឆ្នាំ ដែលមានទុនវិនិយោគជាមធ្យមចំនួន ២២លានដុល្លារអាម៉េរិក ខណៈនៅចន្លោះឆ្នាំ ២០០៩ ដល់ឆ្នាំ២០១២ មានទុនវិនិយោគជាមធ្យមត្រឹមតែ ៤លានដុល្លារអាម៉េរិក ប៉ុណ្ណោះក្នុងមួយឆ្នាំ។ កំណើននៃការវិនិយោគនេះ ក៏បានជំរុញឱ្យមានកំណើនឆាប់រហ័សនៃចំនួនកម្លាំងពលកម្មក្នុងវិស័យយានយន្តផងដែរ ដោយក្នុងនោះកម្លាំងពលកម្មបានកើនឡើងជាមធ្យម ៥០០នាក់ក្នុងមួយឆ្នាំ ដែលបច្ចុប្បន្នមានចំនួនសរុបប្រមាណ ១០.០០០នាក់។ បច្ចុប្បន្ន ជប៉ុន គឺជាប្រភពទុនវិនិយោគសំខាន់ក្នុងវិស័យយានយន្តនៅកម្ពុជា ខណៈដែលទីផ្សារនាំចេញសំខាន់ៗ រួមមានប្រទេសថៃ និងប្រទេសជប៉ុន។

ខណៈដែលវិស័យយានយន្តបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយការចុះបញ្ជីយានយន្តថ្មីធ្លាក់ចុះពី ១០៥.០០០គ្រឿង ក្នុងឆ្នាំ២០១៩ មកត្រឹម ៨៦.០០០ គ្រឿង ក្នុងឆ្នាំ២០២០, ការព្យាកររយៈពេលវែងសម្រាប់វិស័យយានយន្តនៅកម្ពុជា និងតំបន់អាស៊ាននៅតែមានភាពវិជ្ជមាន ជាមួយនឹងការងើបឡើងវិញ និងកំណើនយ៉ាងឆាប់រហ័សនៅប៉ុន្មានឆ្នាំខាងមុខនេះ ដែលត្រូវបាន

ជំរុញដោយកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងកំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនដែលមានកម្រិតជីវភាពមធ្យម។

ផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើផលិតកម្មយានយន្តនៅកម្ពុជា ក៏ត្រូវបានកាត់បន្ថយផងដែរ ដោយសារកម្មវិធីចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព និងភាពបុរេសកម្មរបស់កម្ពុជា ដែលសម្រេចបានអត្រាចាក់វ៉ាក់សាំងបង្ការខ្ពស់បំផុតទីបីក្នុងអាស៊ាន និងបានចាក់វ៉ាក់សាំងបង្ការប្រមាណ ១០៤% នៃចំនួនប្រជាជនពេញវ័យ ត្រឹមខែវិច្ឆិកា ឆ្នាំ២០២២។ ការណ៍នេះ បានអនុញ្ញាតឱ្យរោងចក្រក្នុងវិស័យយានយន្តជាច្រើននៅកម្ពុជាបន្តសកម្មភាពផលិតកម្មក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩។

**គ្រឿងបង្គុំយានយន្ត÷** ការផលិតនិងផ្គុំដំឡើងគ្រឿងបង្គុំយានយន្តនៅកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំង ជាមួយនឹងកំណើននាំចេញជាមធ្យមប្រចាំឆ្នាំ ៣៦% ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។ កំណើននេះត្រូវបានជំរុញជាចម្បងដោយការផលិត និងការនាំចេញខ្សែបង្គុំអគ្គិសនីសម្រាប់យានយន្ត ដែលជាសកម្មភាពអតិពលកម្ម។ ទោះយ៉ាងនេះក្តី ក៏មានសញ្ញាណវិជ្ជមានផងដែរ នៃសក្តានុពលកំណើននៅក្នុងវិស័យដែលមានតម្លៃបន្ថែមខ្ពស់ ដូចជា គ្រឿងបង្គុំម៉ាស៊ីនយានយន្ត (Powertrain components) ដែលបានកើនឡើងដល់ ១០% នៃការនាំចេញគ្រឿងបង្គុំយានយន្តពីកម្ពុជាក្នុងឆ្នាំ២០១៩។

ក្រុមហ៊ុនផលិតនិងផ្គុំដំឡើងគ្រឿងបង្គុំយានយន្តធំៗ រួមមានក្រុមហ៊ុន Denso, Yazaki, Sumitomo និង Kyungshin ជាដើម បាននិងកំពុងធ្វើប្រតិបត្តិការប្រកបដោយជោគជ័យនៅកម្ពុជា តាមរយៈការអនុវត្តយុទ្ធសាស្ត្រប្រទេសបូកមួយ ដោយគ្រឿងបង្គុំដែលត្រូវពឹងផ្អែកលើកម្លាំងអតិពលកម្មត្រូវបានផលិតនៅកម្ពុជាសម្រាប់ផ្គត់ផ្គង់ឱ្យរោងចក្រផ្គុំដំឡើងនៅប្រទេសជិតខាង ដូចជា ថៃ ឬវៀតណាម។

**ការផ្គុំដំឡើងទោចក្រយានយន្ត÷** ជាមួយគ្នានេះ ក៏មានសកម្មភាពផ្គុំដំឡើងទោចក្រយានយន្តនៅកម្ពុជាផងដែរ ដោយបានផ្គុំដំឡើងទោចក្រយានយន្តជាង ៣០០.០០០គ្រឿង ក្នុងឆ្នាំ២០១៩ ដែលភាគច្រើនដំឡើងដោយក្រុមហ៊ុន Honda និង Suzuki។ សកម្មភាពផ្គុំដំឡើងទោចក្រយានយន្តនេះ បានផ្គត់ផ្គង់តម្រូវការក្នុងស្រុកដែលមានកម្រិតខ្ពស់ (ការចុះបញ្ជីទោចក្រយានយន្តថ្មីមានចំនួន ៥៤០.០០០គ្រឿង ក្នុងឆ្នាំ២០១៩) ដែលត្រូវបានរំពឹងទុកថាការលក់ទោចក្រយានយន្តថ្មីនឹងបន្តកើនឡើងដល់ប្រមាណ ១,១លានគ្រឿង នៅឆ្នាំ ២០៣០។ ទោចក្រយានយន្តនៅតែជាជម្រើសមធ្យោបាយដឹកជញ្ជូនដ៏ទាក់ទាញមួយសម្រាប់ប្រជាជនកម្ពុជាដែលមានកម្រិតចំណូលដូចបច្ចុប្បន្ន ខុសពីប្រទេសឯទៀតនៅក្នុងតំបន់ ដែលមានកម្រិតប្រាក់ចំណូលកើនឡើងធ្វើឱ្យអ្នកប្រើប្រាស់ងាកចេញពីការប្រើប្រាស់ទោចក្រយានយន្ត។

ខណៈទោចក្រយានយន្តដែលបានផ្គុំដំឡើងក្នុងស្រុកមានជាង ៨០% នៃតម្រូវការទោចក្រយានយន្តនៅកម្ពុជា បច្ចុប្បន្នគ្រឿងបង្គុំសម្រាប់ទោចក្រយានយន្តភាគច្រើនត្រូវបាននាំចូល។ ទំហំធាតុចូលក្នុងស្រុក មានត្រឹមតែប្រហែលមួយភាគបួននៃតម្លៃទោចក្រយានយន្តសរុបដែលបានផ្គុំដំឡើងនៅកម្ពុជា បើធៀបនឹងប្រទេសផ្សេងទៀតនៅក្នុងតំបន់ដែលមានរហូតដល់ជាង ៨០%។ ការណ៍នេះបង្ហាញពីកាលានុវត្តភាពមួយសម្រាប់កម្ពុជា

ក្នុងការបង្កើនការផលិតគ្រឿងបង្គុំទោចក្រយានយន្តក្នុងស្រុក និងពង្រឹងតួនាទីរបស់ខ្លួននៅក្នុងខ្សែច្រវាក់តម្លៃការផ្គុំដំឡើងទោចក្រយានយន្ត ដោយការពង្រឹងគុណភាពមូលដ្ឋានអ្នកផ្គត់ផ្គង់ក្នុងស្រុក។

**ការផ្គុំដំឡើងរថយន្ត៖** ទោះបីជាកម្ពុជាមានសកម្មភាពផ្គុំដំឡើងរថយន្តក៏ពិតមែន ប៉ុន្តែសកម្មភាពនេះនៅមានបរិមាណតិចតួចនៅឡើយ ដែលអាចបណ្តាលមកពីបញ្ហាប្រឈមមួយចំនួន ដូចជា មូលដ្ឋាននាំចេញតូចចង្អៀត ថ្លៃដើមផលិតកម្មខ្ពស់ ព្រមទាំងតម្រូវការរថយន្តថ្មីក្នុងស្រុកនៅមានចំនួនតិចដោយសារការផ្គត់ផ្គង់រថយន្តមួយទឹកដ៏ច្រើនលើសលប់នៅក្នុងទីផ្សារ។

ទោះបីបញ្ហាប្រឈមទាំងនេះនៅតែជាឧបសគ្គសម្រាប់ការពង្រីកសកម្មភាពផ្គុំដំឡើងរថយន្តក៏ដោយ ប៉ុន្តែ ក្រុមហ៊ុននានា ដូចជាក្រុមហ៊ុនផ្គុំដំឡើងរថយន្តម៉ាក Ford, SsangYong, Isuzu, Hyundai, DongFeng និង Toyota ជាដើម បាននិងកំពុងបង្កើតរោងចក្រផ្គុំដំឡើងនៅកម្ពុជា ដោយមានការប្តេជ្ញាគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល។ បន្ថែមលើនេះ ក៏មានសញ្ញាណវិជ្ជមានផងដែរសម្រាប់សក្តានុពលកំណើនរយៈពេលវែងនៃការផ្គុំដំឡើងរថយន្ត តាមរយៈការកើនឡើងចំណូលចិត្តចំពោះរថយន្តថ្មីក្នុងចំណោមប្រជាជនកម្ពុជា ដែលជំរុញដោយកំណើនប្រាក់ចំណូល និងការបង្កើនការយកចិត្តទុកដាក់របស់អ្នកប្រើប្រាស់ទៅលើសេវាកម្មក្រោយការលក់ និងការធានារបស់រថយន្តថ្មី។

រូបភាពទី២៖ ស្ថានភាពកម្ពុជានាពេលបច្ចុប្បន្ន ក្នុងខ្សែច្រវាក់តម្លៃវិស័យយានយន្ត




ប្រភព៖ ការវិភាគរបស់ក្រុមការងាររាជរដ្ឋាភិបាល និងក្រុមហ៊ុនទីប្រឹក្សា BCG ផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកជំនាញក្នុងវិស័យយានយន្ត

## ២.២. បច្ចុប្បន្នភាពនៃវិស័យអេឡិចត្រូនិក

រូបភាពទី៣÷ ស្ថានភាពបច្ចុប្បន្ននៃវិស័យអេឡិចត្រូនិកនៅកម្ពុជា




ចំណាំ÷ តំនួសតាងមិនមានមាត្រដ្ឋានទេ។

ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

វិស័យអេឡិចត្រូនិកនៅកម្ពុជា មានកំណើនយ៉ាងឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការនាំចេញរបស់វិស័យអេឡិចត្រូនិក ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ បានកើនឡើង ៦ដង រហូតដល់ប្រមាណ ៩២៣លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ខណៈដែលចំនួនគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ បានកើនឡើងរហូតដល់ ៨៩គម្រោង ក្នុងឆ្នាំ២០១៩។ កំណើននៃការវិនិយោគក្នុងវិស័យនេះក៏បានជំរុញឱ្យកម្លាំងពលកម្មកើនឡើងយ៉ាងឆាប់រហ័ស ដល់ទៅ ៧០ដង ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ ហើយសព្វថ្ងៃនេះមានកម្លាំងពលកម្មសរុបប្រមាណ ៣០.០០០នាក់។ បច្ចុប្បន្ននេះ ជប៉ុន និងចិន គឺជាប្រភពទុនវិនិយោគសំខាន់ក្នុងវិស័យអេឡិចត្រូនិកនៅកម្ពុជា ខណៈដែលទីផ្សារនាំចេញសំខាន់ៗ រួមមាន សហរដ្ឋអាមេរិក អាស៊ាន ចិន ជប៉ុន និងកូរ៉េខាងត្បូង។

ខណៈដែលសេដ្ឋកិច្ចកម្ពុជាបានរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ វិស័យអេឡិចត្រូនិកនៅតែមានភាពធន់។ ការព្យាកររយៈពេលវែងសម្រាប់វិស័យអេឡិចត្រូនិកនៅតែរក្សាភាពវិជ្ជមាន ដែលមានកំណើនជាបន្តបន្ទាប់ និងឆាប់រហ័សនៅកម្ពុជា ក៏ដូចជាក្នុងតំបន់អាស៊ាន។ ការព្យាករនេះគឺផ្អែកលើនិន្នាការសំខាន់ៗ ដូចជាកំណើននៃវេខូបនីយកម្មជាដើម ដែលត្រូវបានពន្លឿនបន្ថែមដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើផលិតកម្មអេឡិចត្រូនិកនៅកម្ពុជា ក៏ត្រូវបានកាត់បន្ថយផងដែរ ដោយសារកម្មវិធីចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព និងភាពបុរេសកម្មរបស់កម្ពុជា ដែលសម្រេចបានអត្រាចាក់វ៉ាក់សាំងខ្ពស់បំផុតទីបីក្នុងអាស៊ាន និងបានចាក់វ៉ាក់សាំងប្រមាណ ១០៥% នៃចំនួនប្រជាជនគោលដៅ

ត្រឹមខែវិច្ឆិកា ឆ្នាំ២០២២។ ការណ៍នេះ បានអនុញ្ញាតឱ្យរោងចក្រផលិតបរិក្ខារអេឡិចត្រូនិកជាច្រើននៅកម្ពុជា បន្តសកម្មភាពផលិតកម្មក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩។

**គ្រឿងបង្គុំអេឡិចត្រូនិក÷** ផលិតកម្មគ្រឿងបង្គុំអេឡិចត្រូនិកនៅកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំង ដោយការនាំចេញមានការកើនឡើងក្នុងអត្រា ២០% ក្នុងមួយឆ្នាំ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ដែលត្រូវបានជំរុញជាចម្បងដោយការផលិតខ្សែបង្គុំអគ្គិសនី ខ្សែអំពូល ម៉ូទ័រ និងអំពូលអិលអ៊ីឌី (LED) ដែលជាសកម្មភាពអតិពលកម្ម។ ទោះយ៉ាងនេះក្តី ក៏មានសញ្ញាណវិជ្ជមានផងដែរនៃសក្តានុពលកំណើនក្នុងផ្នែកផលិតកម្មគ្រឿងដំឡើងបន្ទាប់បន្សំ ឬគ្រឿងបង្គុំបន្ទះសៀគ្វីបោះពុម្ពរូប (PCB) ព្រមទាំងការផ្គុំដំឡើងផលិតផលប្រើប្រាស់ផ្សេងទៀត ដូចជាឧបករណ៍បំពងសម្លេង និងម៉ាស៊ីនថតរូប ជាដើម។

ក្រុមហ៊ុនផលិតនិងផ្គុំដំឡើងបរិក្ខារអេឡិចត្រូនិកធំៗ ដូចជាក្រុមហ៊ុន Minebea, SVI, និង Sumitronics ជាដើម បាននិងកំពុងធ្វើប្រតិបត្តិការយ៉ាងជោគជ័យ ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ឬនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ក្រុមហ៊ុនទាំងនេះ បានពង្រីកសកម្មភាពផលិតកម្មមកកម្ពុជា តាមរយៈការអនុវត្តយុទ្ធសាស្ត្រប្រទេសបូកមួយ ឬធ្វើពិពិធកម្មខ្សែច្រវាក់ផ្គត់ផ្គង់ ដោយប្រើប្រាស់ឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា ដូចជាទីតាំងយុទ្ធសាស្ត្រនៅចំកណ្តាលអាស៊ាន និងឧត្តមភាពប្រកួតប្រជែងលើចំណាយថ្លៃដើម។

រូបភាពទី៤÷ ស្ថានភាពរបស់កម្ពុជានាពេលបច្ចុប្បន្ន ក្នុងខ្សែច្រវាក់តម្លៃវិស័យអេឡិចត្រូនិក




ប្រភព÷ ការវិភាគរបស់ក្រុមការងាររាជរដ្ឋាភិបាល និងក្រុមហ៊ុនទីប្រឹក្សា BCG ផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកជំនាញក្នុងវិស័យអេឡិចត្រូនិក

## ២.៣. ឧត្តមភាពប្រកួតប្រជែង

បច្ចុប្បន្ន ឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក រួមមាន កម្លាំងពលកម្មដែលមានភាពប្រកួតប្រជែង ទីតាំងយុទ្ធសាស្ត្រ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានភាពអនុគ្រោះសម្រាប់ការនាំចេញទៅកាន់ទីផ្សារធំៗ ដូចជា អាស៊ាន ចិន ជប៉ុន និងសហរដ្ឋអាមេរិក។

- **កម្លាំងពលកម្មដែលមានភាពប្រកួតប្រជែង÷** ប្រទេសកម្ពុជាមានកម្លាំងពលកម្មវ័យក្មេងច្រើន ដែលមានភាពប្រកួតប្រជែងខ្ពស់ អាចបំពេញតម្រូវការសម្រាប់ផលិតកម្មគ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិក។ ប្រមាណ ៦៤% នៃប្រជាជនចំនួន ១៦លាននាក់ មានអាយុក្រោម ៣៥ឆ្នាំ ហើយប្រាក់ឈ្នួលអប្បបរមានាពេលបច្ចុប្បន្នស្ថិតនៅក្នុងកម្រិតយ៉ាងហោចណាស់ ១០% ទៅ ២០% ទាបជាងមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតសំខាន់ៗដទៃទៀតក្នុងតំបន់។ អត្រាអក្ខរកម្មក្នុងចំណោមមនុស្សពេញវ័យ បានកើនឡើងយ៉ាងឆាប់រហ័សពី៧៨% ក្នុងឆ្នាំ២០០៨ ដល់៨៨% ក្នុងឆ្នាំ២០១៩ ហើយអត្រានេះមានកម្រិតកាន់តែខ្ពស់ក្នុងចំណោមកម្លាំងពលកម្មវ័យក្មេង។ បន្ថែមលើនេះ កម្ពុជាក៏មានបណ្តុំឧស្សាហកម្មកាត់ដេរ ផលិតស្បែកជើង និងកាបូប ដែលបាននិងកំពុងផ្តល់ការងារដល់កម្មករ កម្មការិនីជាង១លាននាក់ ហើយហត្ថកោសល្យ និងវិន័យការងាររបស់ពួកគាត់ អាចប្រើប្រាស់បានក្នុងការផលិតគ្រឿងបង្គុំតូចៗផ្សេងទៀត ក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក។
- **ទីតាំងយុទ្ធសាស្ត្រ÷** ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅត្រង់ចំណុចកណ្តាលនៃតំបន់អាស៊ាន និងមានភាពប្រទាក់ក្រឡាយ៉ាងស៊ីជម្រៅទៅក្នុងខ្សែច្រវាក់តម្លៃតំបន់ តាមរយៈរបៀងសេដ្ឋកិច្ចភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ។ ជាពិសេស ប្រទេសកម្ពុជាស្ថិតនៅជិតមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតយានយន្ត មានចម្ងាយតិចជាង ៤០០គីឡូម៉ែត្រ ពីមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតយានយន្តនៅខេត្តរ៉ាយ៉ង ប្រទេសថៃ និងចម្ងាយតិចជាង ១០០គីឡូម៉ែត្រ ពីទីក្រុងហូជីមិញ ប្រទេសវៀតណាម។ ការណ៍នេះ ធ្វើឱ្យប្រទេសកម្ពុជាក្លាយជាទីតាំងដ៏ល្អបំផុតសម្រាប់រោងចក្រផលិតកម្មដែលផ្គត់ផ្គង់ដល់រោងចក្រផ្គុំដំឡើងយានយន្តនៅប្រទេសថៃ និង/ឬ វៀតណាម។ ជាមួយគ្នានេះ ផ្អែកលើកត្តាភូមិសាស្ត្រនេះ កម្ពុជាគឺជាទីតាំងដ៏ល្អមួយសម្រាប់បង្កើតរោងចក្រផលិតគ្រឿងដំឡើងបន្ទាប់បន្សំ និងគ្រឿងបង្គុំអេឡិចត្រូនិកផ្សេងៗ ផ្គត់ផ្គង់ឱ្យរោងចក្រដែលស្ថិតនៅមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងអេឡិចត្រូនិកនៃប្រទេសទាំងពីរ។
- **កិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានភាពអនុគ្រោះ÷** កម្ពុជាមានសេដ្ឋកិច្ចបើកចំហ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានភាពអនុគ្រោះ សម្រាប់ការនាំចេញទៅទីផ្សារយានយន្ត និងអេឡិចត្រូនិកធំៗ ហើយក៏បានទាញយកប្រយោជន៍ពីប្រព័ន្ធអនុគ្រោះពន្ធរបស់បណ្តាប្រទេសអភិវឌ្ឍន៍ និងអង្គការអន្តររដ្ឋាភិបាលមួយចំនួននៅលើសកលលោក សម្រាប់ការនាំចេញយានយន្ត និងអេឡិចត្រូនិក។ ប្រទេសកម្ពុជាក៏ជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគីដូចជា កិច្ចព្រមព្រៀងតំបន់

ពាណិជ្ជកម្មសេរីអាស៊ាន កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានបូក (ASEAN Plus) ជាមួយនឹងប្រទេសអូស្ត្រាលី-នូវែលសេឡង់ ចិន ហុងកុង ឥណ្ឌា ជប៉ុន និងសាធារណរដ្ឋកូរ៉េ និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។ ជាមួយគ្នានេះ កម្ពុជាក៏មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋកូរ៉េ ហើយកម្ពុជាក៏បាននិងកំពុងចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសដៃគូដទៃ ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មទៅក្នុងខ្សែច្រវាក់តម្លៃតំបន់និងសកល។

## ជំពូកទី៣៖ ចក្ខុវិស័យ គន្លងអភិវឌ្ឍន៍ និងគោលដៅ

### ៣.១. ចក្ខុវិស័យ

កម្ពុជាមានចក្ខុវិស័យក្នុងការប្រែក្លាយជា **មជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងបង្គុំយានយន្ត និងបរិក្ខារអេឡិចត្រូនិក** សម្រាប់នាំចេញទៅទីផ្សារក្នុងតំបន់ និងសកលលោក។ ក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យនៃវិស័យទាំងពីរនេះ កម្ពុជានឹងកសាងសមត្ថភាពដើម្បីឈានឡើងក្នុងខ្សែច្រវាក់តម្លៃ ដោយផ្លាស់ប្តូរពីការផលិត និងដំឡើងគ្រឿងបង្គុំយានយន្ត និងបរិក្ខារអេឡិចត្រូនិកសាមញ្ញៗបែបអតិពលកម្ម ទៅការផលិតនិងដំឡើងគ្រឿងបង្គុំនិងបរិក្ខារដែលមានតម្លៃបន្ថែមកាន់តែខ្ពស់ជាងមុន តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាផលិតកម្មទំនើបជាងមុននិងកម្លាំងពលកម្មដែលមានជំនាញខ្ពស់ ព្រមទាំងការប្រកាន់យកអភិក្រមដែលកាន់តែផ្តោតលើចីរភាពបរិស្ថានក្នុងកម្មន្តសាលនៃវិស័យទាំងពីរផងដែរ។

ការសម្រេចនូវចក្ខុវិស័យនេះ នឹងនាំមកនូវផ្លែផ្កាវិជ្ជមានសម្រាប់សង្គម-សេដ្ឋកិច្ច ជាពិសេសការបង្កើនតម្លៃបន្ថែមក្នុងស្រុក ការបង្កើនភាពធន់របស់សេដ្ឋកិច្ចជាតិ ការចូលរួមលើកកម្ពស់ការធ្វើពិពិធកម្មនិងទំនើបកម្មឧស្សាហកម្ម និងការផ្តល់ឱកាសការងារប្រកបដោយជំនាញកាន់តែច្រើនដល់ប្រជាជនកម្ពុជា។

### ៣.២. គន្លងអភិវឌ្ឍន៍ និងគោលដៅនៃវិស័យយានយន្ត

កម្ពុជានឹងឈានទៅសម្រេចបានចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ក្នុងការប្រែក្លាយទៅជា **មជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងបង្គុំយានយន្ត** តាមដំណាក់កាលចំនួនពីរ។

រូបភាពទី៥៖ គន្លងអភិវឌ្ឍន៍ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃវិស័យយានយន្តកម្ពុជា




ប្រភព៖ ការវិភាគរបស់ក្រុមការងាររាជរដ្ឋាភិបាល និងក្រុមហ៊ុនទីប្រឹក្សា BCG ផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកជំនាញក្នុងវិស័យយានយន្ត

**ក. ដំណាក់កាលទី១÷ គ្រឿងបង្គុំសាមញ្ញ, ការដំឡើងទោចក្រយានយន្ត និងការតភ្ជាប់បែបប្រតិគមន៍**

**អនុវិស័យចម្បង÷** សម្រាប់រយៈពេលខ្លី (៥ឆ្នាំខាងមុខ) កម្ពុជា នឹងផ្តោតលើការប្រើប្រាស់ឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដើម្បីចាប់យកកាលានុវត្តភាពបច្ចុប្បន្នក្នុងផ្នែកសំខាន់ៗចំនួនពីរ÷

**ទីមួយ÷ កម្ពុជានឹងឈានទៅពង្រីកមូលដ្ឋានផ្គត់ផ្គង់គ្រឿងបង្គុំយានយន្តដែលមានលក្ខណៈសាមញ្ញ បែបអតិពលកម្ម សម្រាប់បម្រើឱ្យការនាំចេញ។ គ្រឿងបង្គុំទាំងនោះរួមមាន ÷**

- ខ្សែបង្គុំអគ្គិសនី
- កៅអីយានយន្ត
- គ្រឿងបង្គុំអេឡិចត្រូនិក និងអគ្គិសនីសាមញ្ញ ដែលប្រើប្រាស់ក្នុងយានយន្តដូចជា ឧបករណ៍ផ្តល់សញ្ញា, កុងតាក់, និងឧបករណ៍បញ្ជូនព័ត៌មាន ជាដើម។

ការផលិតគ្រឿងបង្គុំដែលមានលក្ខណៈអតិពលកម្មបែបនេះ គឺមានភាពសមស្របទៅនឹងបរិបទកម្ពុជា ដោយសារប្រាក់ឈ្នួលកម្លាំងពលកម្មមានភាពប្រកួតប្រជែង ហើយសកម្មភាពទាំងនេះក៏មិនទាមទារឱ្យមានកម្រិតបច្ចេកវិទ្យាខ្ពស់ផងដែរ។ ម្យ៉ាងវិញទៀត គ្រឿងបង្គុំទាំងនេះក៏មានទម្ងន់ស្រាល ដែលធ្វើឱ្យចំណាយសម្រាប់ការនាំចេញទៅកាន់រោងចក្រផ្គុំដំឡើងនៅក្រៅប្រទេសមានតម្លៃទាបអាចទទួលយកបាន ពិសេសការនាំចេញទៅកាន់ប្រទេសជិតខាង។ ទោះបីជាគ្រឿងបង្គុំទាំងនេះជាចំណែកតូចៗរបស់យានយន្តក្តី ក៏គ្រឿងបង្គុំទាំងនេះអាចក្លាយជាកាលានុវត្តភាពលេចធ្លោដែលកម្ពុជាគួរចាប់យក ដោយសារទីផ្សារគ្រឿងបង្គុំទាំងនេះបាននិងកំពុងរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយក្រុមហ៊ុនផ្គត់ផ្គង់ផលិតផលគ្រឿងបង្គុំក៏បាននិងកំពុងតែធ្វើពិពិធកម្មមូលដ្ឋានផលិតកម្មយ៉ាងសកម្ម ដើម្បីពង្រឹងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួន។

**ទីពីរ÷ កម្ពុជានឹងឈានទៅបង្កើនសកម្មភាពផ្គុំដំឡើងទោចក្រយានយន្ត ដើម្បីពង្រីកការតភ្ជាប់បែបប្រតិគមន៍ និងពង្រីកមូលដ្ឋានផ្គត់ផ្គង់គ្រឿងបង្គុំក្នុងស្រុកសម្រាប់បម្រើឱ្យសកម្មភាពផ្គុំដំឡើងទោចក្រយានយន្ត។**

នាពេលបច្ចុប្បន្ន ប្រព័ន្ធអេកូឡូស៊ីនៃអ្នកផ្គត់ផ្គង់គ្រឿងបង្គុំក្នុងស្រុក សម្រាប់ការផ្គុំដំឡើងទោចក្រ-យានយន្តនៅកម្ពុជា នៅមានលក្ខណៈថ្មីថ្មោង ហើយការតភ្ជាប់រវាងអ្នកផ្គត់ផ្គង់គ្រឿងបង្គុំ ជាមួយនឹងអ្នកផ្គុំដំឡើងក្នុងស្រុកនៅមានកម្រិតនៅឡើយ។ ក្រុមហ៊ុនផ្គុំដំឡើងទោចក្រយានយន្ត និង អ្នកផ្គត់ផ្គង់កម្រិតទី១ (Tier 1) បានលើកឡើងពីកង្វល់អំពីគុណភាពនៃគ្រឿងបង្គុំដែលផលិតដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក។ អាស្រ័យហេតុនេះ គ្រឿងបង្គុំទោចក្រយានយន្តភាគច្រើនត្រូវបាននាំចូល ចំណែកឯទំហំធាតុចូលក្នុងស្រុកបានរួមចំណែកត្រឹមតែមួយភាគបួនប៉ុណ្ណោះនៃតម្លៃគ្រឿងបង្គុំសរុបសម្រាប់ការផ្គុំដំឡើងទោចក្រយានយន្តនៅកម្ពុជា។

ដូច្នេះ ការពង្រឹងប្រព័ន្ធអេកូឡូស៊ីនៃអ្នកផ្គត់ផ្គង់គ្រឿងបង្គុំក្នុងស្រុកសម្រាប់ការផ្គុំដំឡើងទោចក្រយានយន្ត ពិតជាមានសារៈសំខាន់ណាស់ ក្នុងការបង្កើនចំណែកនៃធាតុចូលក្នុងស្រុក និងបង្កើនផលប្រយោជន៍ក្នុងស្រុក

ទប់ស្កាត់វិហូរចេញនៃប្រយោជន៍សេដ្ឋកិច្ចទៅខាងក្រៅ។ ការណ៍នេះនឹងអនុញ្ញាតឱ្យប្រទេសកម្ពុជាចាប់យកតម្លៃបន្ថែមក្នុងសកម្មភាពផ្គុំដំឡើងទោចក្រយានយន្តបន្ថែមទៀត តាមរយៈកត្តាជំរុញចំនួនបី។ កត្តាជំរុញទីមួយគឺ កំណើនតម្រូវការទោចក្រយានយន្តសរុប នឹងបន្តកើនឡើងជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ រហូតដល់ឆ្នាំ២០២៥។ កត្តាជំរុញទីពីរគឺ ការកើនឡើងនៃអត្រាទោចក្រយានយន្តដែលផ្គុំដំឡើងក្នុងស្រុក។ ជាក់ស្តែងក្នុងពេលបច្ចុប្បន្ន ៨២% នៃទោចក្រយានយន្តសរុបដែលកំពុងចរាចរក្នុងទីផ្សារ ត្រូវបានផ្គុំដំឡើងក្នុងស្រុក ហើយកម្ពុជាមានគោលដៅបង្កើនអត្រានេះឱ្យបានដល់ ៩៥% នៅត្រឹមឆ្នាំ២០២៥។ កត្តាជំរុញទីបីគឺ ការកើនឡើងនៃចំណែកនៃធាតុផ្សំក្នុងស្រុក។ ដើម្បីឈានទៅកម្រិតមួយប្រហាក់ប្រហែលនឹងប្រទេសក្នុងតំបន់ ចំណែកនេះត្រូវកើនឡើងពី ២៦% ក្នុងពេលបច្ចុប្បន្ន ទៅអត្រាគោលដៅ ៨៥% ត្រឹមឆ្នាំ២០២៥។

**ខ. ដំណាក់កាលទី២ - គ្រឿងបង្គុំយានយន្តដែលមានលក្ខណៈស្មុគស្មាញជាងមុន**

ក្នុងរយៈពេលមធ្យមទៅវែង កម្ពុជាមានគោលដៅឈានឡើងក្នុងខ្សែច្រវាក់តម្លៃយានយន្ត ពីសកម្មភាពផលិតគ្រឿងបង្គុំដែលមានលក្ខណៈសាមញ្ញនិងអតិពលកម្មទៅរកសកម្មភាពផលិតគ្រឿងបង្គុំដែលមានលក្ខណៈស្មុគស្មាញ និងមានតម្លៃបន្ថែមខ្ពស់ជាងមុន។

**អនុវិស័យចម្បង៖** ក្នុងដំណាក់កាលនេះ កម្ពុជានឹងទាក់ទាញសកម្មភាពផលិតគ្រឿងបង្គុំយានយន្តដែលមានលក្ខណៈស្មុគស្មាញកម្រិតមធ្យម ពិសេសគ្រឿងបង្គុំ ដែលមានទម្ងន់ស្រាល និងមិនសូវងាយរងផលប៉ះពាល់ពីការប្រែប្រួលនៃថ្លៃដឹកជញ្ជូន ដែលមានភាពប្រកួតប្រជែងផ្នែកតម្លៃ ហើយសមស្របសម្រាប់ការនាំចេញទៅកាន់មជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផ្គុំដំឡើងយានយន្តនៅប្រទេសជិតខាង។

គ្រឿងបង្គុំទាំងនោះ រួមមាន៖

- រ៉ាឌីយ៉ាទ័រ និងប្រព័ន្ធកម្តៅ (radiators and thermal systems)
- ប្រព័ន្ធអេឡិចត្រូនិកសម្រាប់បញ្ជូនព័ត៌មាន និងរក្សាសុវត្ថិភាព (communications and safety electronics)
- ឧបករណ៍បំប្លែងអគ្គិសនី និងអាំងវឺតទ័ររបស់យានយន្តអគ្គិសនី (EV convertors and invertors)
- ដុំបញ្ជាយានយន្តអគ្គិសនី (EV vehicle control units)
- ម៉ូទ័រអគ្គិសនីយានយន្តអគ្គិសនី (ការចាក់ពុម្ព និងផ្គុំដំឡើង)
- បណ្តុំបន្ទុះអាគុយយានយន្តអគ្គិសនី (ការចាក់ពុម្ព និងការផ្គុំដំឡើង)។

រូបភាពទី៦÷ គ្រឿងបង្គុំមានលក្ខណៈស្មុគស្មាញជាងមុនដែលកម្ពុជាអាចពិចារណាផលិត ដើម្បីឈានឡើងក្នុងខ្សែច្រវាក់តម្លៃនៃវិស័យយានយន្ត

| | យានយន្តដើរដោយចំហេះ(ICE) | គ្រឿងបង្គុំដែលយានយន្តដើរដោយចំហេះ និងយានយន្តអគ្គិសនីមានដូចគ្នា | យានយន្តអគ្គិសនី (EV) |
|---|---|---|---|
| មានភាពស្មុគស្មាញជាងគេក្នុងការផលិត | • ម៉ាស៊ីន<br>• ប្រព័ន្ធចលនាយានយន្ត(Drivetrain)<br>• ប្រព័ន្ធចំហេះ(Fuel System) | • កម្មវិធីអេឡិចត្រូនិក (Electronics software)<br>• ប្រព័ន្ធភ្ជាប់តួយានយន្តជាមួយកង់ (suspension) | • បន្ទះអាគុយ (Battery cells)<br>• ប្រព័ន្ធហ្វ្រាំង (Energy regen braking system)<br>• ដុំម៉ូទ័រអគ្គិសនី (Electric motor core)<br>• ប្រព័ន្ធគ្រប់គ្រងកម្តៅ (Thermal management system)<br>• ភ្លៅរបស់ យានយន្តអគ្គិសនី (E-axle) |
| មានភាពស្មុគស្មាញមធ្យមក្នុងការផលិត(កម្ពុជាអាចមានលទ្ធភាពផ្នែកបច្ចេកវិទ្យាក្នុងការផលិតក្នុងរយៈពេលតិចជាង១០ឆ្នាំ) | • ប្រព័ន្ធបញ្ចេញផ្សែង (Exhaust system) | • គ្រោងយានយន្ត (Body structure)<br>• ហ្វ្រាំង (Brakes)<br>• សំបកកង់ (Tires)<br>• រ៉ាឌីយ៉ាទ័រ / ប្រព័ន្ធកម្តៅ (Radiators / thermal systems)<br>• ប្រព័ន្ធអេឡិចត្រូនិកសម្រាប់បញ្ជូនព័ត៌មាននិងរក្សាសុវត្ថិភាព (Communications and safety electronics) | • ការចាក់ពុម្ព និងដំឡើងម៉ូទ័រអគ្គិសនី (Electric motor casing & assembly)<br>• ឧបករណ៍បំប្លែងអគ្គិសនី និងអាំងវឺតទ័រ<br>• ការចាក់ពុម្ព និងដំឡើងបណ្តុំបន្ទះអាគុយ (Battery pack casing & assembly)<br>• ដុំបញ្ជាយានយន្ត (Vehicle control unit) |
| មានភាពស្មុគស្មាញតិចជាងគេក្នុងការផលិត | | • ខ្សែបង្គុំអគ្គិសនី<br>• កៅអីយានយន្ត<br>• បរិក្ខារអគ្គិសនីសាមញ្ញ (ឧទាហរណ៍ ឧបករណ៍ចាប់សញ្ញា, កុងតាក់, ប្រព័ន្ធអេឡិចត្រូនិកសម្រាប់បញ្ជូនព័ត៌មាននិងរក្សាសុវត្ថិភាពដែលមានលក្ខណៈសាមញ្ញ) | គ្រឿងអេឡិចត្រូនិកយានយន្ត រួមមានគ្រឿងបង្គុំយានយន្តអគ្គិសនី គឺជាឱកាសពន្លឺះក្នុងការឈានឡើងក្នុងខ្សែច្រវាក់តម្លៃ និងមានសក្តានុពលខ្ពស់សម្រាប់ការនាំចេញ ដោយគ្រឿងបន្លាស់ទាំងនោះមានទម្ងន់ស្រាល និងមិនសូវងាយរងផលប៉ះពាល់ពីការប្រែប្រួលនៃតម្លៃដឹកជញ្ជូន |

ប្រភព÷ ការវិភាគរបស់ក្រុមការងាររាជរដ្ឋាភិបាល និងក្រុមហ៊ុនទីប្រឹក្សា BCG ផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកជំនាញក្នុងវិស័យយានយន្ត

ការកើនឡើងនៃយានយន្តអគ្គិសនី និងទីផ្សារដែលមានតម្លៃពី ២៥០ ដល់ ៣០០ពាន់លានដុល្លារអាម៉េរិក សម្រាប់គ្រឿងបង្គុំយានយន្តអគ្គិសនី ដែលនឹងលេចឡើងនៅត្រឹមឆ្នាំ២០៣០ នឹងផ្តល់កាលានុវត្តភាពដ៏សំខាន់ដល់កម្ពុជាក្នុងការឈានឡើងក្នុងខ្សែច្រវាក់តម្លៃគ្រឿងបង្គុំយានយន្ត។ ខណៈដែលគ្រឿងបង្គុំសំខាន់ៗសម្រាប់យានយន្តដែលប្រើប្រាស់ម៉ាស៊ីនចំហេះក្នុង មានភាពស្មុគស្មាញខ្ពស់ និងមានទម្ងន់ធ្ងន់ តួយ៉ាងដូចជាម៉ាស៊ីន និងប្រព័ន្ធចលនាយានយន្ត (drivetrain) ដែលការផលិតនៅកម្ពុជាអាចជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន គ្រឿងបង្គុំយានយន្តអគ្គិសនីភាគច្រើន ជាគ្រឿងបង្គុំដែលមានភាពស្មុគស្មាញកម្រិតមធ្យម និងមានទម្ងន់ស្រាលជាង ដែលកម្ពុជាអាចមានភាពប្រកួតប្រជែងផ្នែកតម្លៃ សម្រាប់ការផលិតនៅក្នុងទសវត្សរ៍ខាងមុខ។

បន្ថែមលើនេះ បច្ចុប្បន្នកម្ពុជាបាននិងកំពុងទាក់ទាញក្រុមហ៊ុនផលិតខ្សែបង្គុំអគ្គិសនីសំខាន់ៗជាច្រើនរួចស្រេច ដែលក្រុមហ៊ុនទាំងនោះបាននិងកំពុងស្វែងរកឱកាសពង្រីកអាជីវកម្មរបស់ខ្លួនទៅកាន់ការផលិតគ្រឿងបង្គុំអេឡិចត្រូនិក និងអគ្គិសនីដែលមានតម្លៃបន្ថែមខ្ពស់សម្រាប់យានយន្តអគ្គិសនី។ ការដាក់ចេញនូវគោលនយោបាយនិងការលើកទឹកចិត្តដែលមានលក្ខណៈសមស្រប អាចលើកទឹកចិត្តឱ្យក្រុមហ៊ុនទាំងនោះបន្តនាំយកសកម្មភាពផលិតគ្រឿងបង្គុំដែលមានតម្លៃបន្ថែមខ្ពស់ទាំងនោះមកកម្ពុជា។ ចំពោះទោចក្រយានយន្ត

ប្រព័ន្ធអេកូឡូស៊ីនៃអ្នកផ្គត់ផ្គង់គ្រឿងបង្គុំក្នុងស្រុក ក៏នឹងអាចគាំទ្រដល់ការផលិតគ្រឿងបង្គុំមានលក្ខណៈស្មុគស្មាញជាងមុន ដូចជាការផ្គុំដំឡើងបណ្តុំបន្ទុះអាគុយសម្រាប់ទោចក្រយានយន្តអគ្គិសនី។

ក្រៅពីគ្រឿងបង្គុំខាងលើ កម្ពុជាអាចទាក់ទាញសកម្មភាពផលិតគ្រឿងបង្គុំដទៃទៀតដែលមានលក្ខណៈស្មុគស្មាញកម្រិតមធ្យម ប៉ុន្តែអាចនឹងងាយរងផលប៉ះពាល់ពីការប្រែប្រួលនៃថ្លៃដឹកជញ្ជូនជាងគ្រឿងបង្គុំដទៃ ដូចជាផ្នែកខ្លះនៃគ្រោងយានយន្ត ហ្វ្រាំង និងសំបកកង់យានយន្ត ក៏ដូចជាប្រព័ន្ធបញ្ចេញផ្សែងសម្រាប់យានយន្តដែលប្រើប្រាស់ម៉ាស៊ីនចំហេះក្នុងជាដើម។

**ផលជះ និងសមត្ថភាពដែលនឹងត្រូវបានកសាងសម្រាប់ដំណាក់កាលទាំងពីរ÷** ដើម្បីសម្រេចចក្ខុវិស័យ និងគន្លងអភិវឌ្ឍន៍ខាងលើ រាជរដ្ឋាភិបាលកម្ពុជាកំណត់យកគោលដៅចម្បងពីរ ក្នុងការវាស់វែង÷

- ការបង្កើនទំហំនាំចេញក្នុងវិស័យយានយន្តឱ្យបានចំនួន ៥០០លានដុល្លារអាមេរិក នៅត្រឹមឆ្នាំ ២០២៧
- ការបង្កើតការងារថ្មីសម្រាប់មុខតំណែងដែលត្រូវការជំនាញបច្ចេកទេសទាប មធ្យម និងខ្ពស់ ចំនួន ១០.០០០ កន្លែង នៅត្រឹមឆ្នាំ២០២៧។

ការផ្តោតលើកាលានុវត្តភាពបច្ចុប្បន្នសម្រាប់រយៈពេលខ្លីនិងមធ្យម នឹងជួយឱ្យកម្ពុជាទាក់ទាញសកម្មភាពផលិតថ្មីៗ និងជំរុញការបង្កើតឧត្តមភាពប្រកួតប្រជែងថ្មីៗ ព្រមទាំងធ្វើឱ្យកម្ពុជាឈានទៅសម្រេចចក្ខុវិស័យរយៈពេលវែងក្នុងការអភិវឌ្ឍវិស័យយានយន្ត។ ផលជះដែលកម្ពុជារំពឹងទទួលបានតាមរយៈការអភិវឌ្ឍវិស័យនេះតាមដំណាក់កាលដូចបានរៀបរាប់ខាងលើ មានដូចតទៅ÷

- **ការបង្កើតបាននូវមូលដ្ឋានអ្នកផ្គត់ផ្គង់គ្រឿងបង្គុំដែលមានគុណភាពខ្ពស់ក្នុងស្រុកសម្រាប់ផ្គត់ផ្គង់តម្រូវការសកម្មភាពផ្គុំដំឡើងទោចក្រយានយន្ត÷** កម្ពុជានឹងធ្វើការវិនិយោគក្នុងការបង្កើនគុណភាពអ្នកផ្គត់ផ្គង់ក្នុងស្រុក ព្រមទាំងជំរុញការសាយភាយបច្ចេកវិទ្យាពីក្រុមហ៊ុនផ្គុំដំឡើងទោចក្រយានយន្ត និងអ្នកផ្គត់ផ្គង់កម្រិតទី១
- **ការកើនឡើងនៃចំនួនកម្លាំងពលកម្មជំនាញក្នុងវិស័យយានយន្ត÷** ចំនួនអ្នកគ្រប់គ្រង បុគ្គលិកបច្ចេកទេស និងប្រតិបត្តិករដែលមានចំណេះដឹងក្នុងដំណើរការផលិតកម្ម និងស្តង់ដារគុណភាពសម្រាប់ការផលិតគ្រឿងបង្គុំយានយន្ត មានការកើនឡើង ព្រមទាំងអាចមានសមត្ថភាពក្នុងការធ្វើប្រតិបត្តិការផលិតគ្រឿងបង្គុំដែលមានលក្ខណៈកាន់តែស្មុគស្មាញជាងមុនបន្ថែមទៀត។ ជាមួយគ្នានេះ កម្ពុជានឹងមានកម្លាំងពលកម្មដែលមានជំនាញនិងបទពិសោធន៍បច្ចេកទេសកម្រិតមធ្យមច្រើនជាងមុន ពិសេសវិស្វករ និងអ្នកបច្ចេកទេស ដែលទទួលបានការបណ្តុះបណ្តាលផ្នែកមេកានិក ឬអេឡិចត្រូនិក

- **ការរីកដុះដាលនៃចង្កោមអ្នកផ្គត់ផ្គង់គ្រឿងបង្គុំយានយន្តនៅកម្ពុជា÷** កម្ពុជាផ្តល់ការគាំទ្រយ៉ាងពេញទំហឹង និងកសាងភាពជាដៃគូជាមួយអ្នកផលិតគ្រឿងបង្គុំទាំងនេះ ដោយចាប់ផ្តើមពីសកម្មភាពផលិតគ្រឿងបង្គុំដែលមានលក្ខណៈសាមញ្ញបែបអតិពលកម្ម ឈានឆ្ពោះទៅជំរុញឱ្យមានសកម្មភាពផលិតគ្រឿងបង្គុំដែលមានតម្លៃបន្ថែមខ្ពស់ សម្រាប់រយៈពេលខាងមុខ។ គោលដៅចម្បងនៃកិច្ចខិតខំប្រឹងប្រែងនេះ គឺដើម្បីចាប់ផ្តើមការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃអ្នកផលិតកៅអី និងឧបករណ៍អេឡិចត្រូនិកសម្រាប់យានយន្ត ដែលសកម្មភាពផលិតប្រភេទនេះពុំសូវមានវត្តមានច្រើននាពេលបច្ចុប្បន្ន។ កម្ពុជា ក៏មានបំណងទាក់ទាញក្រុមហ៊ុនផលិតគ្រឿងបង្គុំយានយន្តឈានមុខគេលើពិភពលោក ក្នុងចំនួនច្រើនជាងមុន ហើយអាចនឹងបង្កើតប្រព័ន្ធអេកូឡូស៊ីដែលមានភាពពេញលក្ខណៈជាងមុន សម្រាប់គាំទ្រក្រុមហ៊ុនផលិតទាំងនោះ ដោយរួមបញ្ចូលអ្នកផ្គត់ផ្គង់ក្នុងស្រុកពីកម្រិតទាបទៅមធ្យម (កម្រិតទី២ (Tier 2) និងទី៣ (Tier 3))។

ក្រៅពីការបង្កើតលក្ខខណ្ឌសមស្របដើម្បីគាំទ្រកម្ពុជាក្នុងការប្រែក្លាយជាមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងបង្គុំយានយន្ត គុណសម្បត្តិដែលកើតចេញពីប្រព័ន្ធអេកូឡូស៊ីនៃអ្នកផលិតគ្រឿងបង្គុំ និងការកើនឡើងនៃកម្លាំងពលកម្មជំនាញ ក៏នឹងអាចជួយឱ្យកម្ពុជាទាក់ទាញសកម្មភាពផ្គុំដំឡើងរថយន្តបានច្រើនជាងមុន។ ទោះបីតម្រូវការក្នុងស្រុកនៅមានកម្រិត ដែលធ្វើឱ្យការផ្គុំដំឡើងរថយន្តនៅកម្ពុជា មិនទាន់មានភាពប្រកួតប្រជែងផ្នែកតម្លៃ និងជួបផលលំបាកជាច្រើនក្តី ប៉ុន្តែនិន្នាការដែលកើតឡើងថ្មីៗនៅក្នុងវិស័យយានយន្ត អាចកែប្រែស្ថានភាពនេះក្នុងរយៈពេលវែង។ ជាក់ស្តែង ការលេចឡើងនូវប្រភេទយានយន្តអគ្គិសនីដែលមានតម្លៃទាប និងការផ្លាស់ប្តូរចំណង់ចំណូលចិត្តរបស់អតិថិជន អាចពន្លឿនកំណើនតម្រូវការរថយន្តថ្មីនៅកម្ពុជា ខណៈដែលម៉ូដែលផលិតកម្មប្រភេទថ្មីដូចជា “រោងចក្រខ្នាតមីក្រូ” (micro-factories) ដែលកើតចេញពីបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤អាចនឹងធ្វើឱ្យការផ្គុំដំឡើងខ្នាតតូចប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធភាពផ្នែកតម្លៃ។

### ៣.៣. គន្លងអភិវឌ្ឍន៍ និងគោលដៅនៃវិស័យអេឡិចត្រូនិក

កម្ពុជានឹងឈានទៅរកចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ក្នុងការប្រែក្លាយជា **មជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតបរិក្ខារអេឡិចត្រូនិក** តាមដំណាក់កាលចំនួនពីរ។

រូបភាពទី៧÷ គន្លងអភិវឌ្ឍន៍ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃវិស័យអេឡិចត្រូនិកកម្ពុជា




ប្រភព÷ ការវិភាគរបស់ក្រុមការងាររាជរដ្ឋាភិបាល និងក្រុមហ៊ុនទីប្រឹក្សា BCG ផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកជំនាញក្នុងវិស័យអេឡិចត្រូនិក

## ក. ដំណាក់កាលទី១÷ គ្រឿងបង្គុំសាមញ្ញ និងគ្រឿងដំឡើងបន្ទាប់បន្សំ

**អនុវិស័យចម្បង÷** សម្រាប់រយៈពេលខ្លី (៥ឆ្នាំខាងមុខ) កម្ពុជា នឹងផ្តោតលើការប្រើប្រាស់ឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដើម្បីចាប់យកកាលានុវត្តភាពបច្ចុប្បន្ន ដោយឈានទៅពង្រីកមូលដ្ឋានផលិតកម្មគ្រឿងអេឡិចត្រូនិក ដែលផ្តោតលើការផលិតគ្រឿងបង្គុំដែលមានលក្ខណៈសាមញ្ញ និងគ្រឿងបង្គុំបន្ទាប់បន្សំ ដូចជា ខ្សែភ្លើងនិងខ្សែតំណ និងបន្ទះសៀគ្វីបោះពុម្ពរួចជាដើម។ នៅក្នុងដំណាក់កាលនេះ គោលបំណងសំខាន់គឺជំរុញការកសាងមូលដ្ឋានសម្រាប់ការអភិវឌ្ឍវិស័យអេឡិចត្រូនិក តាមរយៈក្រុមហ៊ុនផលិតបរិក្ខារអេឡិចត្រូនិកដែលកំពុងមានប្រតិបត្តិការនៅកម្ពុជាស្រាប់ និងដែលមានបទពិសោធក្នុងការផលិតផលិតផលទាំងបីខាងលើ។

គ្រឿងបង្គុំអេឡិចត្រូនិកដែលត្រូវបានកំណត់ជាអនុវិស័យចម្បងសម្រាប់ដំណាក់កាលនេះ មានទម្ងន់ស្រាលនិងទំហំតូច ដែលស័ក្តិសមសម្រាប់ការនាំចេញ ហើយសមស្របទៅនឹងគោលដៅរបស់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍវិស័យអេឡិចត្រូនិកដែលផ្តោតលើការផលិតដើម្បីនាំចេញ។ គ្រឿងបង្គុំទាំងនេះ ក៏ត្រូវបានផ្គត់ផ្គង់សម្រាប់ផលិតកម្មនៃផលិតផលសម្រេចជាច្រើន ទៅតាមកម្រិតនៃផលិតកម្ម ដែលកត្តានេះអាចជួយឱ្យវិស័យអេឡិចត្រូនិករបស់កម្ពុជាកាន់តែធន់នឹងវិបត្តិ ហើយក៏អាចក្លាយជាឈ្នាន់សម្រាប់កម្ពុជាឈានទៅចាប់យកសកម្មភាពផលិតបរិក្ខារអេឡិចត្រូនិកដែលមានលក្ខណៈកាន់តែស្មុគស្មាញបន្ថែមទៀត។

គោលដៅរបស់កម្ពុជាគឺទាក់ទាញក្រុមហ៊ុនផ្តល់សេវាកម្មផលិតគ្រឿងអេឡិចត្រូនិក (Electronics Manufacturing Services) ដែលមានសមត្ថភាពនិងបទពិសោធក្នុងការផលិតបរិក្ខារ និងគ្រឿងបង្គុំអេឡិច-

ត្រូនិកជាច្រើនប្រភេទ ដូចជាផលិតកម្មគ្រឿងបង្គុំដែលពុំសូវស្មុគស្មាញច្រើន គ្រឿងបង្គុំបន្ទាប់បន្សំ និងមុខសញ្ញាផលិតកម្មដទៃជាច្រើនទៀត។

### ខ. ដំណាក់កាលទី២÷ ការរចនា និងសកម្មភាពផ្គុំដំឡើងដែលមានតម្លៃខ្ពស់ជាងមុន

**អនុវិស័យចម្បង÷** ក្នុងរយៈពេលពីមធ្យមទៅវែង កម្ពុជាមានគោលដៅឈានឡើងក្នុងខ្សែច្រវាក់តម្លៃអេឡិចត្រូនិក ទៅរកសកម្មភាពផ្គុំដំឡើង និងសេវាកម្មលើការរចនា ដែលមានតម្លៃបន្ថែមខ្ពស់ជាងមុន ដើម្បីផ្គត់ផ្គង់សកម្មភាពឧស្សាហកម្មឱ្យកាន់តែទូលំទូលាយ។ ក្នុងន័យនេះ អនុវិស័យចម្បងដែលកម្ពុជាអាចពិចារណាបន្ថែម មានដូចជា÷

- ការពង្រីកទៅរកផលិតផលអេឡិចត្រូនិកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងក្នុងវិស័យឧស្សាហកម្មនិងការតភ្ជាប់បណ្តាញ ដែលមានលក្ខណៈស្មុគស្មាញជាងមុន ដើម្បីចាប់យកទីផ្សារដែលមានទំហំធំ និងមានកំណើនខ្ពស់ ជាពិសេសគឺផ្នែកកំណើនថ្មី ដែលកើតចេញពីបច្ចេកវិទ្យា៥G
- ការពង្រីកទៅរកការផលិតគ្រឿងបង្គុំអេឡិចត្រូនិកសម្រាប់យានយន្ត ដែលមានកម្រិតខ្ពស់ជាងមុន÷ ផ្នែកគ្រឿងអេឡិចត្រូនិកសម្រាប់យានយន្តមានកំណើន និងសក្តានុពលខ្ពស់ ដែលជំរុញដោយការកើនឡើងនៃយានយន្តអគ្គិសនី និងកាលានុវត្តភាពក្នុងការបន្តធ្វើសមាហរណកម្មទៅក្នុងខ្សែច្រវាក់តម្លៃយានយន្តក្នុងតំបន់
- ការពង្រីកទៅរកគ្រឿងអេឡិចត្រូនិកសម្រាប់បច្ចេកវិទ្យាវេជ្ជសាស្ត្រ ជាពិសេសគ្រឿងបង្គុំអេឡិចត្រូនិកកម្រិតដំបូង ព្រោះនេះជាផ្នែកដែលមានកំណើនខ្ពស់ និងជាឱកាសសម្រាប់កម្ពុជាក្នុងការធ្វើសមាហរណកម្មទៅក្នុងខ្សែច្រវាក់តម្លៃសកល។ បន្ថែមពីលើការពង្រីកសមត្ថភាពផលិត កម្ពុជាមានមហិច្ឆតាក្នុងការឈានទៅរកសកម្មភាពក្នុងខ្សែច្រវាក់តម្លៃបន្ថែមខ្ពស់ ដូចជាសេវាកម្មលើការរចនាជាដើម។ ក្នុងករណីនេះ កម្ពុជាមានគោលដៅទាក់ទាញឱ្យបានច្រើនជាងមុននូវក្រុមហ៊ុនធំៗវិនិយោគលើការរចនាបរិក្ខារអេឡិចត្រូនិក (Original Design Manufacturers) និងក្រុមហ៊ុនធំៗផលិតបរិក្ខារអេឡិចត្រូនិក (Original Equipment Manufacturers) ដែលដើរតួយ៉ាងសំខាន់ក្នុងការផ្តល់សេវាកម្មទាំងនេះ។ សកម្មភាពទាំងនេះ ត្រូវបានរំពឹងថានឹងបំពេញបន្ថែមប្រព័ន្ធអេកូឡូស៊ីនៃក្រុមហ៊ុនផលិតក្នុងស្រុក។

រូបភាពទី៨÷ អនុវិស័យចម្បងដែលកម្ពុជាអាចពិចារណាផលិតដើម្បីឈានឡើងក្នុងខ្សែច្រវាក់តម្លៃនៃ
វិស័យអេឡិចត្រូនិក




ប្រភព÷ ការវិភាគរបស់ក្រុមការងាររាជរដ្ឋាភិបាល និងក្រុមហ៊ុនទីប្រឹក្សា BCG ផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកជំនាញក្នុងវិស័យអេឡិចត្រូនិក

**ផលជះ និងសមត្ថភាពដែលនឹងត្រូវបានកសាងសម្រាប់ដំណាក់កាលទាំងពីរ÷** ដើម្បីសម្រេចចក្ខុវិស័យ និងគន្លងអភិវឌ្ឍន៍ខាងលើ រាជរដ្ឋាភិបាលកម្ពុជាកំណត់យកគោលដៅចម្បងពីរ ក្នុងការវាស់វែង÷

- ការបង្កើនទំហំនាំចេញក្នុងវិស័យអេឡិចត្រូនិកឱ្យបាន ១,៦ពាន់លានដុល្លារអាមេរិក នៅត្រឹមឆ្នាំ២០២៧
- ការបង្កើតការងារថ្មីសម្រាប់មុខតំណែងដែលត្រូវការជំនាញទាប មធ្យម និងខ្ពស់ ចំនួន ១៦.០០០កន្លែង នៅត្រឹមឆ្នាំ២០២៧។

សម្រាប់រយៈពេលខ្លី និងមធ្យម កម្ពុជានឹងកសាងមូលដ្ឋានឧត្តមភាពប្រកួតប្រជែងថ្មីៗជាគោលដៅដើម្បីឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យនៃការអភិវឌ្ឍវិស័យអេឡិចត្រូនិក។ ផលជះដែលកម្ពុជារំពឹងទទួលបាន តាមរយៈការអភិវឌ្ឍវិស័យនេះ តាមដំណាក់កាលដូចបានរៀបរាប់ខាងលើ មានដូចតទៅ÷

- **ការកើនឡើងនៃចំនួនកម្លាំងពលកម្មជំនាញក្នុងវិស័យអេឡិចត្រូនិក÷** កម្ពុជានឹងមានក្រុមវិស្វករមានជំនាញ និងបទពិសោធច្រើនជាងមុន ជាពិសេសវិស្វករដែលមានបទពិសោធក្នុងការផលិត និងរចនា។ ជាមួយគ្នានេះ ចំនួនបុគ្គលិកកម្មករជំនាញ ក្នុងផ្នែកគ្រប់គ្រងផលិតកម្ម អ្នកបច្ចេកទេស អ្នកគ្រប់គ្រងកម្រិតមធ្យម ដែលមានបទពិសោធក្នុងដំណើរការផលិតកម្ម ដូចជា

ការដំឡើងគ្រឿងបង្គុំអេឡិចត្រូនិកនៅលើបន្ទះសៀគ្វីបោះពុម្ពរួច ដោយប្រើប្រាស់ Surface Mount Technology និងការគ្រប់គ្រងបណ្តាញផលិតកម្មជាដើម ក៏នឹងមានការកើនឡើងផងដែរ

- **ការរីកដុះដាលនៃចង្កោមក្រុមហ៊ុនផ្តល់សេវាកម្មផលិតគ្រឿងអេឡិចត្រូនិកនៅកម្ពុជា÷** កម្ពុជាផ្តល់ការគាំទ្រយ៉ាងពេញទំហឹង និងកសាងភាពជាដៃគូជាមួយក្រុមហ៊ុនផលិតកម្មកម្រិតដំបូង ដែលផលិតគ្រឿងបង្គុំអេឡិចត្រូនិក និងគ្រឿងបង្គុំបន្ទាប់បន្សំ។ ភាពជាដៃគូទាំងនេះនឹងផ្តោតសំខាន់ជាពិសេសលើក្រុមហ៊ុនផ្តល់សេវាកម្មផលិតបរិក្ខារអេឡិចត្រូនិកកម្រិតកណ្តាល។ កម្ពុជាក៏មានបំណងទាក់ទាញឱ្យបានកាន់តែទូលំទូលាយនូវក្រុមហ៊ុនផ្តល់សេវាកម្មផលិតគ្រឿងអេឡិចត្រូនិក (Electronic Manufacturing Services), ក្រុមហ៊ុនរចនា និងផលិតបរិក្ខារអេឡិចត្រូនិក (Original Design Manufacturers) និងក្រុមហ៊ុនផលិតបរិក្ខារអេឡិចត្រូនិកតាមការបញ្ជាទិញ (Original Equipment Manufacturers) ដែលមានបទពិសោធក្នុងផ្នែកផលិតកម្មដែលមានកម្រិតខ្ពស់ជាងមុន ដើម្បីពង្រឹងប្រព័ន្ធអេកូឡូស៊ីអ្នកផលិត។

ក្រៅពីការបង្កើតលក្ខខណ្ឌសមស្របដើម្បីគាំទ្រកម្ពុជាក្នុងការប្រែក្លាយជាមជ្ឈមណ្ឌលប្រមូលផ្តុំសកម្មភាពផលិតគ្រឿងអេឡិចត្រូនិក ការកសាងសមត្ថភាពទាំងនេះក៏នឹងអាចជួយទាក់ទាញក្រុមហ៊ុនផលិតគ្រឿងបង្គុំបន្ទះអេឡិចត្រូនិក (board component) កម្រិតខ្ពស់ ដែលអាចជួយកម្ពុជាធ្វើសមាហរណកម្មឈានឡើងក្នុងខ្សែច្រវាក់តម្លៃនៃការផលិតគ្រឿងអេឡិចត្រូនិកដែលមានលក្ខណៈពេញលេញ (upstream integration)។

## ជំពូកទី៤÷ បញ្ហាប្រឈមក្នុងការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកនៅកម្ពុជា

បញ្ហាប្រឈមចម្បងមួយចំនួនកំពុងបង្អាក់ដល់ការរីកចម្រើននៃវិស័យយានយន្ត និងអេឡិចត្រូនិកនៅកម្ពុជា។ បញ្ហាប្រឈមភាគច្រើនប៉ះពាល់មិនត្រឹមតែមកលើវិស័យយានយន្ត និងអេឡិចត្រូនិកប៉ុណ្ណោះទេ ប៉ុន្តែមកលើការអភិវឌ្ឍវិស័យឧស្សាហកម្មជារួម។

### ៤.១. ភាពចាំបាច់ឱ្យមានយុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន

ដើម្បីអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកឱ្យបានពេញលេញ ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងភាគីពាក់ព័ន្ធដែលរួមមាន ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអន្តរជាតិនានា ព្រមទាំងវិស័យឯកជន ដូចជាសហព័ន្ធធុរកិច្ចនិងវិនិយោគិន ជាដើម។ បច្ចុប្បន្ន គម្លាតក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការសម្របសម្រួលវិស័យយានយន្ត និងអេឡិចត្រូនិកដែលត្រូវដោះស្រាយ រួមមាន÷

**ក. តម្រូវការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យរយៈពេលវែង÷** មកទល់បច្ចុប្បន្ន កម្ពុជាពុំទាន់មានចក្ខុវិស័យរយៈពេលវែង និងគន្លងអភិវឌ្ឍន៍ សម្រាប់វិស័យយានយន្តនិងអេឡិចត្រូនិកនៅឡើយទេ។ អវត្តមាននៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យរយៈពេលវែង បានបង្អាក់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យទាំងនេះ និងបានធ្វើឱ្យវិនិយោគិនពុំមានទំនុកចិត្តគ្រប់គ្រាន់លើការប្តេជ្ញាចិត្តរយៈពេលវែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យទាំងនេះ។

ដូច្នេះហើយ ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក ដែលបានដាក់ចេញនូវចក្ខុវិស័យរយៈពេលវែង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទាំងនេះ គឺជាជំហានដំបូងដ៏សំខាន់ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ។ យុទ្ធសាស្ត្រនេះ នឹងបន្តមានការកែលម្អ ផ្អែកលើមតិយោបល់និងធាតុចូលដែលរាជរដ្ឋាភិបាលប្រមូលបានពីវិនិយោគិនជាបន្តបន្ទាប់។

**ខ. តម្រូវការយុទ្ធសាស្ត្រអភិវឌ្ឍន៍ចង្កោមឧស្សាហកម្មតាមវិស័យ÷** កម្ពុជាមិនទាន់មានយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការអភិវឌ្ឍចង្កោមវិស័យយានយន្ត ឬអេឡិចត្រូនិកនៅលើទីតាំងជាក់លាក់ណាមួយនៅឡើយទេ។ ជាក់ស្តែង រោងចក្រក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក ស្ថិតនៅរាយប៉ាយទូទាំងប្រទេស នៅតាមទីតាំងផ្សេងៗគ្នា និងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនានា ដែលបណ្តាលឱ្យបាត់បង់ឱកាសទទួលបានឥទ្ធិពលជាវិជ្ជមានពីការដែលរោងចក្រក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក មានទីតាំងនៅជិតគ្នា។ ឥទ្ធិពលជាវិជ្ជមានទាំងនេះមានដូចជា÷

- លទ្ធភាពក្នុងការចែករំលែកហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធអេកូឡូស៊ីគាំទ្រ ស្របតាមតម្រូវការរបស់វិស័យនីមួយៗ (ឧទាហរណ៍ ការបង្កើតគ្រឹះស្ថាន អ.ប.វ. និងមជ្ឈមណ្ឌលឧត្តមភាពក្នុងវិស័យយានយន្ត ដែលស្ថិតនៅជិតចង្កោមឧស្សាហកម្មវិស័យយានយន្ត)

- ការធ្វើសមាហរណកម្មកាន់តែជិតស្និទ្ធរវាងក្រុមហ៊ុនផលិតកម្មផ្នែកផ្សេងៗគ្នាក្នុងខ្សែច្រវាក់តម្លៃសម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក
- ការបង្កើននវានុវត្តន៍ដែលកើតចេញពីការរៀនសូត្រពីគ្នាទៅវិញទៅមក និងការចែករំលែកព័ត៌មាន។

ដូច្នេះ កម្ពុជាមានភាពចាំបាច់ក្នុងការកំណត់ទីតាំងឬតំបន់សេដ្ឋកិច្ចពិសេស ដើម្បីអភិវឌ្ឍឱ្យក្លាយជាចង្កោមផលិតកម្មសម្រាប់វិស័យនីមួយៗ។

**គ. តម្រូវការយុទ្ធសាស្ត្រទាក់ទាញវិនិយោគិនដែលមានភាពបុរេសកម្ម៖** ផ្នែកមួយនៃបញ្ហាប្រឈមរបស់កម្ពុជាក្នុងការទាក់ទាញការវិនិយោគពីបរទេសក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក គឺកង្វះការយល់ដឹងអំពីសក្តានុពល កាលានុវត្តភាព និងភាពអំណោយផលក្នុងការវិនិយោគនៅកម្ពុជា ក្នុងចំណោមវិនិយោគិនសក្តានុពល។

ទោះបីជាកម្ពុជាបាននិងកំពុងបន្តកែលម្អបរិយាកាសវិនិយោគនិងធុរកិច្ចក៏ដោយ ក៏នៅមានភាពចាំបាច់ក្នុងការធ្វើឱ្យវិនិយោគិនសក្តានុពលយល់ដឹងអំពីវឌ្ឍនភាពនិងកាលានុវត្តភាពវិនិយោគនៅកម្ពុជា ហើយធ្វើការសម្រេចចិត្តវិនិយោគដោយមិនផ្អែកលើការយល់ឃើញខុស ឬផ្អែកលើស្ថានភាពកម្ពុជាពីអតីតកាល។ ក្នុងបរិការណ៍នេះ ចាំបាច់ត្រូវមានយុទ្ធនាការទាក់ទាញនិងផ្សព្វផ្សាយទៅកាន់វិនិយោគិនសក្តានុពលក្នុងវិស័យយានយន្តនិងអេឡិចត្រូនិកដែលមានភាពកាន់តែបុរេសកម្ម ជាពិសេសវិនិយោគិនក្នុងអនុវិស័យអាទិភាពនានាក្នុងការតម្រង់ទិសគន្លងអភិវឌ្ឍន៍វិស័យទាំងនេះ។

**ឃ. តម្រូវការយុទ្ធសាស្ត្រភាពជាដៃគូក្នុងតំបន់៖** កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិកនាពេលបច្ចុប្បន្ន នៅមិនទាន់មានភាពប្រទាក់ក្រឡាគ្នាល្អជាមួយដៃគូក្នុងតំបន់ ដូចជាប្រទេសថៃ និងវៀតណាម ដែលជាទីផ្សារសក្តានុពលដ៏សំខាន់សម្រាប់គ្រឿងបង្គុំយានយន្តនិងអេឡិចត្រូនិកផលិតនៅកម្ពុជា ហើយដែលជាផ្នែកនៃយុទ្ធសាស្ត្រប្រទេសបូកមួយ។ បញ្ហាប្រឈមជាច្រើនដែលវិនិយោគិនជួបប្រទះ ដូចជា ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងភស្តុភារកម្ម អាចត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាពតាមរយៈយន្តការទ្វេ ឬពហុភាគី ជាជាងរាជរដ្ឋាភិបាលកម្ពុជាដោះស្រាយបញ្ហាដោយខ្លួនឯង។ ដោយយុទ្ធសាស្ត្រក្នុងវិស័យយានយន្តនិងអេឡិចត្រូនិករបស់កម្ពុជាផ្តោតលើការនាំចេញ កម្ពុជាចាំបាច់ត្រូវបង្កើតយុទ្ធសាស្ត្រពង្រឹងភាពជាដៃគូជាមួយប្រទេសជិតខាងសម្រាប់ទទួលបានផលប្រយោជន៍ពីគ្នាទៅវិញទៅមកពីការអភិវឌ្ឍវិស័យទាំងពីរនេះ។

## ៤.២. ធនធានមនុស្ស និងនវានុវត្តន៍

កង្វះខាតធនធានមនុស្ស គឺជាបញ្ហារាំងស្ទះដ៏ចម្បងមួយទៀតសម្រាប់ការអភិវឌ្ឍវិស័យយានយន្តនិង អេឡិចត្រូនិកនៅកម្ពុជា។ ដើម្បីពង្រីកវិស័យនេះ កម្ពុជាចាំបាច់ត្រូវបង្កើនធនធានមនុស្សដែលមានការ បណ្តុះបណ្តាល និងបទពិសោធនៅគ្រប់កម្រិត រាប់បញ្ចូលទាំងកម្មករ អ្នកបច្ចេកទេស វិស្វករ និងអ្នកគ្រប់គ្រង។

**ក. តម្រូវការបង្កើនចំនួនកម្លាំងពលកម្មជំនាញ និងអ្នកបច្ចេកទេសកម្រិតមធ្យម÷** ឧត្តមភាពប្រកួត-ប្រជែងមួយរបស់កម្ពុជា គឺកម្លាំងពលកម្មដែលមានតម្លៃប្រកួតប្រជែងខ្ពស់ បើធៀបនឹងប្រទេសផ្សេងទៀតនៅក្នុងតំបន់។ ការកែលម្អវិស័យអប់រំ ក៏បានធ្វើឱ្យអត្រាអក្ខរកម្ម និងអត្រានៃការចេះគិតលេខមានភាពប្រសើរឡើងផងដែរ។ ឧទាហរណ៍ អត្រាអក្ខរកម្មសម្រាប់មនុស្សពេញវ័យបានកើនឡើងយ៉ាងឆាប់រហ័សពី ៧៨% ក្នុងឆ្នាំ២០០៨ ដល់ ៨៨% ក្នុងឆ្នាំ២០១៩។ ទោះជាយ៉ាងនេះក្តី វិនិយោគិននៅតែបន្តជួបបញ្ហាប្រឈមពាក់ព័ន្ធនឹងការស្វែងរក និងរក្សាកម្លាំងពលកម្មដែលមានជំនាញ និងពុំមានជំនាញនៅក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក និងវិស័យឧស្សាហកម្មផ្សេងទៀត។ ដូចនេះ កម្ពុជាមានភាពចាំបាច់ក្នុងការចាត់វិធានការដើម្បីបង្កើនឱ្យបានឆាប់រហ័សនូវចំនួនកម្លាំងពលកម្មនិងអ្នកបច្ចេកទេសកម្រិតមធ្យម ដែលមានជំនាញនិងបទពិសោធសមស្រប សម្រាប់បម្រើការងារក្នុងវិស័យយានយន្ត និងអេឡិចត្រូនិកប្រកបដោយផលិតភាព។

នៅកម្រិតមូលដ្ឋានបំផុត ចាំបាច់ត្រូវរៀបចំឱ្យកម្មករ និយោជិតដែលធ្លាប់បម្រើការក្នុងវិស័យកសិកម្ម និងសេវាកម្ម យល់ដឹងអំពីទម្លាប់និងវិន័យការងារសម្រាប់បម្រើការនៅក្នុងវិស័យកម្មន្តសាល។ ជាមួយគ្នានេះ ប្រព័ន្ធ អ.ប.វ. គួរតែបំពាក់និងពង្រឹងជំនាញបច្ចេកទេសរបស់កម្មករ និយោជិត (ឧទាហរណ៍ ជំនាញកុំព្យូទ័រមូលដ្ឋាន ជំនាញអេឡិចត្រូនិក និងមេកានិចក្នុងការប្រើប្រាស់និងថែទាំគ្រឿងម៉ាស៊ីនផលិតកម្ម) ដើម្បីត្រៀមឱ្យពួកគាត់ចាប់យកមុខតំណែងដែលមានជំនាញខ្ពស់។ កម្ពុជា ក៏មានសក្តានុពលក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) កម្រិតដំបូង សម្រាប់សិស្សវិទ្យាល័យ ដើម្បីត្រៀមឱ្យពួកគាត់ទទួលបានការបណ្តុះបណ្តាលនិងការអប់រំបន្ថែម តាមរយៈប្រព័ន្ធ អ.ប.វ. ឬសាកលវិទ្យាល័យ។

លើសពីនេះ ការពង្រឹងសេវាផ្គូផ្គងការងារនិងជ្រើសរើសបុគ្គលិក ក៏មានភាពចាំបាច់ដើម្បីដោះស្រាយបញ្ហាទីផ្សារការងារតាមភូមិសាស្ត្រដែលមិនមានភាពសមាមាត្រនៅកម្ពុជា ដែលបណ្តាលឱ្យកន្លែងខ្លះជួបប្រទះនឹងកង្វះកម្លាំងពលកម្មជំនាញ ហើយកន្លែងខ្លះទៀតសម្បូរកម្លាំងពលកម្មជំនាញលើសលប់។ កម្ពុជាក៏មានកម្លាំងពលកម្មជំនាញ និងមានបទពិសោធយ៉ាងច្រើនដែលកំពុងបម្រើការងារក្នុងវិស័យយានយន្តនិង អេឡិច-ត្រូនិកនៅប្រទេសជិតខាង ដែលនេះជាឱកាសអាចឱ្យកម្ពុជាពង្រីកចំនួនពលកម្មជំនាញ ដោយទាញយកកម្លាំងពលកម្មជំនាញដែលមានស្រាប់។

**ខ. កង្វះអ្នកបច្ចេកទេសផ្នែកវិស្វកម្ម គ្រប់គ្រង និងជំនាញវិជ្ជាជីវៈ÷** វិនិយោគិនក្នុងវិស័យយានយន្ត និងអេឡិចត្រូនិកនៅកម្ពុជា ក៏ជួបបញ្ហាប្រឈមក្នុងការជ្រើសរើសកម្មករ និយោជិតក្នុងតួនាទីការងារដែល

ទាមទារកម្រិតចំណេះដឹងបច្ចេកទេស ឬជំនាញវិជ្ជាជីវៈខ្ពស់ ដូចជាវិស្វករ អ្នកគ្រប់គ្រងរោងចក្រ និងបុគ្គលិករដ្ឋបាល។ តាមបទពិសោធជាក់ស្តែង វិនិយោគិនបរទេសនាំយកវិស្វករ និងអ្នកជំនាញមកពីបរទេស ជាពិសេសនៅក្នុងដំណាក់កាលដំបូងនៃការបង្កើតរោងចក្រថ្មី។ អ្នកជំនាញបរទេសទាំងនេះគឺជាប្រភពដ៏សំខាន់សម្រាប់បង្កើតដំណើរការការងារនៅក្នុងរោងចក្រថ្មីទាំងនេះ និងជាអ្នកបណ្តុះបណ្តាលកម្មករ និយោជិតកម្ពុជា ដើម្បីត្រៀមបំពេញតួនាទីដែលត្រូវការជំនាញខ្ពស់ទាំងនេះ។

ដូច្នេះ កម្ពុជាចាំបាច់ត្រូវបង្កើតគោលនយោបាយនិងផែនការ ដើម្បីបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការទាក់ទាញអ្នកបច្ចេកទេសដែលមានជំនាញខ្ពស់បែបនេះ ដោយរួមបញ្ចូលទាំងផែនការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជាការថែទាំសុខភាពនិងការអប់រំ ជាពិសេស នៅតាមទីជនបទ និងដើម្បីទាក់ទាញអ្នកបច្ចេកទេសខ្មែរដែលរស់នៅក្រៅប្រទេស និងកម្មករចំណាកស្រុកកម្ពុជាដែលមានជំនាញនិងបទពិសោធសមស្របក្នុងវិស័យយានយន្តនិងអេឡិចត្រូនិកឱ្យត្រឡប់មកកម្ពុជាវិញ។

## ៤.៣. ហេដ្ឋារចនាសម្ព័ន្ធ

ទោះបីជាហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់កម្ពុជាមានភាពកាន់តែប្រសើរឡើង អាទិភាពរយៈពេលខ្លីសំខាន់បំផុតដែលបានលើកឡើងដោយវិនិយោគិនក្នុងវិស័យយានយន្តនិងអេឡិចត្រូនិក គឺការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្ម ខណៈដែលកម្ពុជាត្រូវបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនលើផ្នែកមួយចំនួនទៀត រួមទាំងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដូចជាអ៊ីនធឺណិតល្បឿនលឿនដើម្បីគាំទ្រដល់ការផ្លាស់ប្តូរទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើជំនាញខ្ពស់។

**ក. តម្រូវការក្នុងការធ្វើឱ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី÷** អាទិភាពចម្បង ដែលជាការលើកឡើងរបស់វិនិយោគិនគឺការកាត់បន្ថយថ្លៃអគ្គិសនី និងការបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់។ ក្នុងរយៈពេល ៥ ទៅ ១០ឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងការធ្វើឱ្យប្រសើរឡើងនូវវិសាលភាពនិងស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី ក៏ដូចជាការបញ្ចុះថ្លៃអគ្គិសនី។ ឧទាហរណ៍ សន្ទស្សន៍នៃភូមិដែលទទួលបានការផ្គត់ផ្គង់អគ្គិសនី បានកើនឡើងយ៉ាងខ្លាំងពី ៦៦,៦% ក្នុងឆ្នាំ២០១៥ ដល់ ៩៧,៤% ក្នុងឆ្នាំ២០២០។ ថ្លៃអគ្គិសនីក៏បានថយចុះដល់ទៅ ៣០% ផងដែរក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ។ លើសពីនេះ ជាង ៥០% នៃផលិតកម្មថាមពលក្នុងស្រុករបស់កម្ពុជាបានមកពីប្រភពកកើតឡើងវិញ (ភាគច្រើនគឺ វារីអគ្គិសនី) ដែលជាអត្រាខ្ពស់មួយនៅក្នុងតំបន់ និងជាការផ្តល់គុណតម្លៃដ៏សំខាន់មួយសម្រាប់វិនិយោគិនដែលចង់កាត់បន្ថយផលប៉ះពាល់របស់ខ្លួនដល់បរិស្ថាន ។

ទោះជាយ៉ាងនេះក្តី ថ្លៃអគ្គិសនីនៅកម្ពុជានៅតែស្ថិតនៅកម្រិតមួយខ្ពស់ ហើយស្ថិរភាពនៃការផ្គត់ផ្គង់ក៏ស្ថិតនៅកម្រិតមួយទាប បើធៀបនឹងប្រទេសជិតខាង។ ខណៈគម្លាតនេះកំពុងតែរួមតូចទៅ ការខិតខំប្រឹងប្រែងរួមរបស់រាជរដ្ឋាភិបាលគឺជាការចាំបាច់ ដើម្បីធ្វើឱ្យថ្លៃអគ្គិសនីមានភាពប្រកួតប្រជែង និងការផ្គត់ផ្គង់អគ្គិសនី

មានស្ថិរភាព សំដៅធានាបាននូវការចំណាយដែលមានភាពប្រកួតប្រជែង និងជៀសវាងការរំខានដល់ប្រតិបត្តិការផលិតកម្មនៅក្នុងវិស័យយានយន្តនិងអេឡិចត្រូនិកដែលពឹងផ្អែកខ្លាំងលើការប្រើប្រាស់ថាមពល។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី ដែលមានភាពកាន់តែប្រសើរឡើង ក៏ដូចជាការធ្វើពិពិធកម្មទៅរកប្រភពថាមពលថ្មីៗ (ឧទាហរណ៍ ថាមពលពន្លឺព្រះអាទិត្យ និងថាមពលកកើតឡើងវិញផ្សេងទៀត) គឺជាការចាំបាច់។

**ខ. តម្រូវការក្នុងការធ្វើឱ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម៖** បញ្ហាប្រឈមសំខាន់មួយទៀតសម្រាប់កម្ពុជា គឺការពង្រឹងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្ម ដើម្បីទ្រទ្រង់ទំហំពាណិជ្ជកម្មដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស និងជាពិសេសដើម្បីគាំទ្រដល់វិស័យដែលផ្តោតលើការនាំចេញដូចជា វិស័យយានយន្ត និងអេឡិចត្រូនិកជាដើម។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មក្នុងប្រទេសកម្ពុជាត្រូវបានកែលម្អនិងធ្វើទំនើបកម្មក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក តាមរយៈការពង្រីកនិងការកែលម្អបណ្តាញផ្លូវ និងការពង្រីកកំពង់ផែសមុទ្រទឹកជ្រៅក្នុងខេត្តព្រះសីហនុ រួមទាំងការដាក់ឱ្យដំណើរការស្ថានីយពហុបំណងកាលពីឆ្នាំ២០១៨។

យ៉ាងណាក៏ដោយ កម្ពុជាក៏នៅអាចមានលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការដឹកជញ្ជូនពហុមធ្យោបាយនិងហេដ្ឋារចនាសម្ព័ន្ធភស្តុភារកម្ម។ ជាក់ស្តែង ការកាត់បន្ថយការកកស្ទះចរាចរណ៍រវាងតំបន់ឧស្សាហកម្មធំៗ ដូចជារាជធានីភ្នំពេញ និងខេត្តព្រះសីហនុ និងការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់រវាងតំបន់ឧស្សាហកម្មទាំងនេះ និងច្រកទ្វារសម្រាប់នាំចេញទៅកាន់ប្រទេសថៃ និងវៀតណាម គឺជាតម្រូវការមួយចាំបាច់។ កង្វះភាពស៊ីចង្វាក់គ្នានៅក្នុងបទប្បញ្ញត្តិនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន បានធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធ កាន់តែជាឧបសគ្គសម្រាប់ការដឹកជញ្ជូន និងភស្តុភារកម្ម។ ជាក់ស្តែង ភាពខុសគ្នានៃទម្ងន់ផ្ទុកអតិបរមា និងការរឹតត្បិតលើចំនួនរថយន្តដឹកទំនិញដែលមានអាជ្ញាបណ្ណដឹកជញ្ជូនឆ្លងដែនរវាងកម្ពុជានិងប្រទេសជិតខាង បានបង្កើនតម្រូវការនៃការផ្លាស់ប្តូររថយន្តដឹកជញ្ជូននៅច្រកព្រំដែន ក៏ដូចជាបានធ្វើឱ្យមានការកកស្ទះនៅមាត់ច្រកព្រំដែន ដែលនាំឱ្យការដឹកជញ្ជូនមានភាពយឺតយ៉ាវ។ ការដោះស្រាយបញ្ហាទាំងនេះនៅក្នុងបណ្តាញដឹកជញ្ជូន អាចនឹងជួយកាត់បន្ថយការចំណាយលើការដឹកជញ្ជូនសម្រាប់ក្រុមហ៊ុនក្នុងវិស័យយានយន្តនិងអេឡិចត្រូនិកនៅកម្ពុជា ជាពិសេសក្រុមហ៊ុនដែលដឹកជញ្ជូនគ្រឿងបង្គុំទៅកាន់រោងចក្រដំឡើងនៅប្រទេសថៃ ឬវៀតណាម។

ខណៈដែលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់បន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកជញ្ជូនទំនិញពាណិជ្ជកម្ម កំពង់ផែនិងអាកាសយានដ្ឋានក៏មានតួនាទីសំខាន់ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យយានយន្ត និងអេឡិចត្រូនិកដែលផ្តោតលើការនាំចេញ និងជាពិសេសសម្រាប់ការឈានទៅចាប់យកគ្រឿងបង្គុំដែលមានតម្លៃបន្ថែមខ្ពស់ និងមានទម្ងន់ស្រាល សមស្របសម្រាប់ការនាំចេញទៅកាន់ទីផ្សារពិភពលោក។ ក្នុងន័យនេះ កម្ពុជាត្រូវបន្តការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្មពហុមធ្យោបាយ ហើយជំរុញការធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដើម្បីធ្វើឱ្យការដឹកជញ្ជូនទំនិញកាន់តែមានប្រសិទ្ធភាព និងចំណាយតិច។

## ៤.៤. កិច្ចសម្រួលពាណិជ្ជកម្ម

កិច្ចសម្រួលពាណិជ្ជកម្មមានសារៈសំខាន់ណាស់ចំពោះយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យយានយន្ត និងអេឡិចត្រូនិកដែលផ្ដោតលើការនាំចេញរបស់កម្ពុជា។ ក្នុងន័យនេះ ការកែទម្រង់កិច្ចសម្រួលពាណិជ្ជកម្មមួយចំនួនត្រូវបានអនុវត្តនាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងនោះរួមមាន ការលុបបំបាត់កម្រៃសេវាគ្រប់គ្រងការនាំចេញ ការលុបបំបាត់ការតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញសម្រាប់ប្រទេសមួយចំនួន ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការផ្ដល់សេវាសាធារណៈ និងការកែទម្រង់ស្ថាប័នសំដៅកាត់បន្ថយចំនួនស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តនីតិវិធីឆ្លងកាត់ព្រំដែន។ ទោះជាយ៉ាងនេះក្ដី កម្ពុជាក៏ត្រូវបន្តធ្វើឱ្យប្រសើរឡើងថែមទៀតនូវនីតិវិធីពាក់ព័ន្ធនឹងការបំពេញបែបបទបញ្ចេញទំនិញ កាត់បន្ថយថ្លៃនិងពេលវេលាក្នុងការដឹកជញ្ជូននាំចេញគ្រឿងបង្គុំយានយន្ត និងផលិតផលអេឡិចត្រូនិក ដើម្បីបង្កើនតម្លាភាពនិងភាពអាចប៉ាន់ប្រមាណបានសម្រាប់វិនិយោគិន។

## ៤.៥. បរិយាកាសធុរកិច្ចនិងវិនិយោគ

ដើម្បីជំរុញការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិកនៅកម្ពុជា ទាមទារឱ្យមានបរិយាកាសធុរកិច្ចនិងវិនិយោគប្រកបដោយភាពទាក់ទាញ និងប្រព័ន្ធអេកូឡូស៊ីដែលអំណោយផលដល់ការរីកចម្រើននៃវិស័យទាំងនេះ ជាពិសេសការតភ្ជាប់ក្នុងខ្សែច្រវាក់តម្លៃ÷

**ក. ការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីការលើកទឹកចិត្តថ្មីក្នុងការវិនិយោគ÷** នៅមុនឆ្នាំ ២០២១ រាជរដ្ឋាភិបាលបានកំណត់ពីតម្រូវការក្នុងការពង្រឹងការលើកទឹកចិត្តវិនិយោគសម្រាប់វិស័យដែលមានតម្លៃបន្ថែមខ្ពស់ និងវិស័យអតិមូលធន (Capital-intensive sectors) រួមទាំងវិស័យយានយន្តនិងអេឡិចត្រូនិកផងដែរ។ ជាក់ស្ដែង នៅមុនឆ្នាំ២០២១ ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាមិនបានផ្ដល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនដែលបានវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការផ្ដល់ការបណ្ដុះបណ្ដាល និងសុខុបត្ថម្ភវត្ថុសម្រាប់កម្មករទេ បើទោះបីជាកត្តាទាំងនេះរួមចំណែកដល់ការអភិវឌ្ឍវិស័យទាំងនេះក៏ដោយ។

ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលត្រូវបានអនុម័តកាលពីចុងឆ្នាំ២០២១ បានដោះស្រាយបញ្ហាទាំងនេះតាមរយៈការផ្ដល់ការលើកទឹកចិត្តដែលកាន់តែមានភាពអំណោយផល និងផ្ដល់នូវមូលដ្ឋានបទប្បញ្ញត្តិកាន់តែរឹងមាំសម្រាប់ការវិនិយោគនៅកម្ពុជា។ អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ទាំងពីរខាងលើកំពុងត្រូវបានរៀបចំ ដើម្បីផ្ដល់ព័ត៌មានលម្អិតបន្ថែម ហើយរាជរដ្ឋាភិបាលនឹងបន្តប្រាស្រ័យទាក់ទងជាមួយសមាគមធុរកិច្ចនៅកម្ពុជា ក៏ដូចជាវិនិយោគិនសក្ដានុពល ដើម្បីជម្រាបជូនពីកាលានុវត្តភាពនានាដែលកើតចេញពីច្បាប់ថ្មីៗទាំងនេះ។

**ខ. តម្រូវការប្រព័ន្ធអេកូឡូស៊ីដែលមានភាពកាន់តែអំណោយផលសម្រាប់ការតភ្ជាប់ក្នុងខ្សែច្រវាក់តម្លៃ÷** កម្ពុជានៅមិនទាន់មានប្រព័ន្ធអេកូឡូស៊ីអំណោយផលសម្រាប់ការតភ្ជាប់ផ្នែកផ្សេងៗនៃខ្សែច្រវាក់តម្លៃយានយន្ត

និងអេឡិចត្រូនិកនៅឡើយ។ ជាក់ស្តែង ទោះបីជាសកម្មភាពផ្គុំដំឡើងទោចក្រយានយន្តនៅកម្ពុជាមានការកើនឡើងក៏ដោយ ក៏ការតភ្ជាប់បែបប្រតិគមន៍រវាងក្រុមហ៊ុនផ្គុំដំឡើងទោចក្រយានយន្តទាំងនោះនិងសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកដែលផ្គត់ផ្គង់គ្រឿងបង្គុំនៅមានកម្រិត ដែលកត្តានេះបានធ្វើឱ្យមានការនាំចូលគ្រឿងបង្គុំភាគច្រើន សម្រាប់ការផ្គុំដំឡើងទោចក្រយានយន្ត។

ក្រុមហ៊ុនផ្គុំដំឡើងភាគច្រើន ពុំមានព័ត៌មានគ្រប់គ្រាន់ពីសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកដែលផ្គត់ផ្គង់គ្រឿងបង្គុំនៅកម្ពុជា ហើយគុណភាពនៃគ្រឿងបង្គុំដែលផលិតនៅកម្ពុជាក៏នៅមានកម្រិតនៅឡើយ។ ការដោះស្រាយនូវកង្វះព័ត៌មាននិងបញ្ហាគម្លាតគុណភាព គឺជាគន្លឹះក្នុងការបង្កើតប្រព័ន្ធអេកូឡូស៊ីដែលអំណោយផលជាងមុនសម្រាប់ការតភ្ជាប់បែបប្រតិគមន៍ក្នុងវិស័យយានយន្ត។ លើសពីនេះ កម្ពុជាគួរជួយជំរុញលទ្ធភាពរបស់សហគ្រាសធុនតូចនិងមធ្យម ក្នុងការផ្តល់សេវាវិស្វកម្មនិងព័ត៌មានវិទ្យាដើម្បីឱ្យក្រុមហ៊ុនទាំងនោះអាចភ្ជាប់ខ្លួនកាន់តែប្រសើរឡើងចូលទៅក្នុងខ្សែច្រវាក់តម្លៃយានយន្ត និងអេឡិចត្រូនិក។ ការណ៍នេះនឹងជួយឱ្យក្រុមហ៊ុនក្នុងស្រុកអាចទទួលបានអត្ថប្រយោជន៍ពីការរីកលូតលាស់នៃវិស័យទាំងពីរនេះ ក៏ដូចជាជំរុញការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃអ្នកផ្តល់សេវាជំនាញគាំទ្រវិស័យទាំងពីរផងដែរ។

## ជំពូកទី៥៖ វិធានការគន្លឹះសម្រាប់អភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក

ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបង្អាក់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាដាក់ចេញនូវផែនការសកម្មភាពអន្តរក្រសួងសម្រាប់អនុវត្តវិធានការគន្លឹះសម្រាប់រយៈពេល ៥ឆ្នាំបន្ទាប់។ ផែនការសកម្មភាពនេះ រំលេចពីការផ្លាស់ប្តូរដ៏សំខាន់ចំនួន២ ចំពោះអភិក្រមរបស់រាជរដ្ឋាភិបាលក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាគោលដៅវិនិយោគលើវិស័យយានយន្តនិងអេឡិចត្រូនិក ដ៏មានភាពទាក់ទាញ។

**បង្កើនការសម្របសម្រួលអន្តរក្រសួង៖** ជាបឋម ផែនការសកម្មភាពរំលេចអំពីភាពចាំបាច់នៃការបង្កើនការសម្របសម្រួលអន្តរក្រសួងដើម្បីអភិវឌ្ឍវិស័យនេះ និងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការិយាធិបតេយ្យដែលមានលក្ខណៈដាច់ដោយដុំដែលធ្លាប់បានបង្អាក់ដល់ដំណើរការនេះ ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ បន្ថែមលើនេះ បើទោះបីជាវិធានការនីមួយៗមានក្រសួងមួយទទួលខុសត្រូវនាំមុខ ប៉ុន្តែការអនុវត្តវិធានការនោះ ក៏ត្រូវមានការចូលរួមពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធផងដែរ។ ក្រុមការងារពន្លឿនវិស័យយានយន្តនិងអេឡិចត្រូនិក ដែលដឹកនាំដោយ ក.អ.ក. ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលអន្តរក្រសួង និងធានានូវវឌ្ឍនភាពនៃការអនុវត្តវិធានការតាមផែនការសកម្មភាពដែលបានដាក់ចេញ។

**ភាពជាដៃគូជិតស្និទ្ធជាមួយវិស័យឯកជន៖** ផែនការសកម្មភាពនេះ ឆ្លុះបញ្ចាំងពីការទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជាថាភាពជាដៃគូជិតស្និទ្ធជាមួយវិស័យឯកជនគឺចាំបាច់សម្រាប់ការរៀបចំនិងការអនុវត្តវិធានការយ៉ាងមានប្រសិទ្ធភាព ដើម្បីអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាបង្កើនការប្រឹក្សាយោបល់ជាមួយវិស័យឯកជន ដើម្បីដោះស្រាយបញ្ហាប្រឈមដែលវិស័យឯកជនជួបប្រទះតាមរយៈការបង្កើត "ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក" ដែលមានសមាសភាពចូលរួមពីស្ថាប័នរដ្ឋ គ្រឹះស្ថាន អ.ប.វ. និងវិស័យឯកជន ដូចជា សមាគមធុរកិច្ចជាតិនិងអន្តរជាតិ ជាដើម ដើម្បីជំរុញដល់ការអភិវឌ្ឍវិស័យទាំងពីរនេះ។

## ក្រុមប្រឹក្សាពិគ្រោះយោបល់តាមវិស័យ ជាអ្នកជំរុញការតម្រង់ទិស និងភាពជាដៃគូជាមួយវិស័យឯកជន

**ផ្អែកលើករណីជោគជ័យជាសកលនៃការសម្របសម្រួលរបស់រាជរដ្ឋាភិបាលជាមួយវិស័យឯកជនលើការអភិវឌ្ឍតាមវិស័យ ក្រុមប្រឹក្សាពិគ្រោះយោបល់តាមវិស័យ មានបេសកកម្មមិនត្រឹមតែជួយសម្រួលការតម្រង់ទិសផ្នែកបច្ចេកទេសលើការអនុវត្តវិធានការប៉ុណ្ណោះទេ ថែមទាំងតម្រង់ទិសយុទ្ធសាស្ត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជនក្នុងការកំណត់ទិសដៅនៃវិស័យ។** ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញតំណាងពីវិស័យឯកជនចូលរួមធ្វើជាសហប្រធាននៃក្រុមប្រឹក្សានេះ សំដៅធានាថាវិស័យឯកជននឹងមានតួនាទីនិងសមត្ថភាព ដើម្បីសម្រេចការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិក។ ក្រុមប្រឹក្សាពិគ្រោះយោបល់តាមវិស័យ នឹងខិតខំសម្រេចឱ្យបានជាបឋមនូវការយល់ឃើញរួមគ្នាអំពីផលប្រយោជន៍និងគោលបំណងរៀងខ្លួនរបស់រាជរដ្ឋាភិបាលនិងវិស័យឯកជន ព្រមទាំងទិសដៅរួមសម្រាប់វិស័យទាំងនេះ មុននឹងឈានដល់ការគិតគូរលើបញ្ហាលម្អិត ដូចជា ការជ្រើសរើសនិងធ្វើអាទិភាវូបនីយកម្មវិធានការសំខាន់ៗ និងតួនាទីរៀងខ្លួនរបស់គូភាគីក្នុងការអនុវត្ត និងសូចនាករដែលអាចវាស់វែងភាពជោគជ័យ។

រូបភាពទី៩÷ ចំណុចនៃការពិភាក្សា ដែលត្រូវដាក់បញ្ចូលក្នុងក្រុមប្រឹក្សាពិគ្រោះយោបល់តាមវិស័យ




ជាកិច្ចចាប់ផ្ដើម វិស័យឯកជនអាចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាលើវិធានការដែលទាមទារនូវការប្ដេជ្ញាផ្នែកហិរញ្ញវត្ថុតិចតួចពីវិស័យឯកជន ដូចជា ការផ្ដល់ធាតុចូលលើកម្រិតជំនាញកម្មករដែលត្រូវការ

ដើម្បីចូលរួមបង្កើតនូវកម្មវិធីសិក្សាលើជំនាញពាក់ព័ន្ធនឹងវិស័យយានយន្ត និងអេឡិចត្រូនិក ឬតម្រូវការចែករំលែកប្រព័ន្ធអេកូឡូស៊ី ដើម្បីចូលរួមរៀបចំផែនការមេអភិវឌ្ឍន៍ចង្កោមឧស្សាហកម្មយានយន្ត និងអេឡិចត្រូនិក។ តាមរយៈការប្តេជ្ញាចិត្តរួមគ្នាជាជំហានៗ ភាពជាដៃគូនេះអាចពង្រីកវិសាលភាពបន្ថែមទៀត ដោយរួមបញ្ចូលនូវវិធានការដែលទាមទារឱ្យមានការប្តេជ្ញាផ្នែកហិរញ្ញវត្ថុកាន់តែច្រើនពីគូភាគី ដូចជា ការបណ្តាក់ទុនរួមគ្នាលើការបង្កើតគ្រឹះស្ថាន អ.ប.វ. ថ្មីសម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក។

បន្ទាត់ពេលវេលានៃការអនុវត្តវិធានការសម្រាប់ជំរុញការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក មានបង្ហាញក្នុងបរិសិដ្ឋទី២។

## ៥.១. យុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន

វិធានការខាងក្រោម មានបំណងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អន្តរក្រសួង ដើម្បីអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក។ អាទិភាពបន្ទាន់ គឺធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន។ ក្នុងន័យនេះ វិធានការអាទិភាព រួមមាន÷

១). រៀបចំឯកសារផែនទីបង្ហាញផ្លូវ ដែលកំណត់យ៉ាងច្បាស់នូវចក្ខុវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក។

២). បង្កើត "ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក" ដែលមានសមាសភាពចូលរួមពីស្ថាប័នរដ្ឋ គ្រឹះស្ថាន អ.ប.វ. និងវិស័យឯកជន ដើម្បីរួមគ្នាជំរុញការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ។

៣). ពង្រឹងការទាក់ទាញវិនិយោគិនដោយបុរេសកម្ម។

៤). កំណត់ទីតាំង ឬតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក។

៥). បង្កើតយុទ្ធសាស្ត្រប្រទេសបូកមួយ ដោយពង្រឹងសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាង ដើម្បីដោះស្រាយបញ្ហាឆ្លងកាត់ព្រំដែនដែលតែងតែកើតមានចំពោះវិនិយោគិន។

៦). ទាក់ទាញ និងសម្រួលវិនិយោគដល់ក្រុមហ៊ុនឈានមុខ។

## ៥.២. ធនធានមនុស្ស និងនវានុវត្តន៍

វិធានការខាងក្រោម មានបំណងគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក។ ភាពជាដៃគូជិតស្និទ្ធជាមួយវិស័យឯកជន មានសារៈសំខាន់ក្នុងការបញ្ចៀសនូវបញ្ហា "មេមាន់និងកូនមាន់" នាពេលបច្ចុប្បន្ន ដែលវិស័យឯកជនស្ទាក់ស្ទើរចំពោះការវិនិយោគនៅកម្ពុជា ដោយសារកង្វះខាតធនធានមនុស្សសមស្រប ខណៈដែលរាជរដ្ឋាភិបាលមើលឃើញពីភាពលំបាកក្នុងការវិនិយោគក្នុងទ្រង់ទ្រាយធំ

លើការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យជាក់លាក់ ប្រសិនបើគ្មានសញ្ញាណច្បាស់លាស់ពីការវិនិយោគឯកជននៅពេលខាងមុខ និងការបង្កើតការងារក្នុងវិស័យទាំងនេះ។ ក្នុងន័យនេះ វិធានការអាទិភាព រួមមាន÷

១). អភិវឌ្ឍកម្មវិធីធ្វើឱ្យប្រសើរឡើងនូវជំនាញនៃកម្លាំងពលកម្មសម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិកដោយសហការជាមួយវិស័យឯកជន។

២). ធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចក្នុងការតាមដាន និងវាយតម្លៃនៃគ្រឹះស្ថាន អ.ប.វ.។

៣). រៀបចំផែនការទាក់ទាញជនបរទេស ទេសន្តប្រវេសន៍ និងអាណិកជនខ្មែរដែលមានទេពកោសល្យ។

៤). ពង្រីក និងពង្រឹងសេវាផ្គូផ្គងការងារ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។

៥). ពង្រីកគ្រឹះស្ថាន អ.ប.វ. នៅតាមតំបន់អាទិភាព។

## ៥.៣. ហេដ្ឋារចនាសម្ព័ន្ធ

វិធានការខាងក្រោម មានគោលបំណងជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដឹកជញ្ជូន និងភស្តុភារកម្ម ដើម្បីគាំទ្រដល់ប្រតិបត្តិការរបស់រោងចក្រក្នុងវិស័យយានយន្ត និងអេឡិចត្រូនិកនៅកម្ពុជា។ ក្នុងន័យនេះ វិធានការអាទិភាព រួមមាន÷

១). អនុវត្តផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី។

២). ពិនិត្យឡើងវិញនូវអត្រាថ្លៃអគ្គិសនី និងស្ថិរភាពនៃការផ្គត់ផ្គង់។

៣). អនុវត្តផែនការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។

៤). ធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិស្ដីពីការដឹកជញ្ជូនផ្លូវគោកឆ្លងកាត់ព្រំដែនជាមួយប្រទេសជិតខាង (ឧទាហរណ៍÷ ប្រទេសថៃ វៀតណាម និងឡាវ)។

## ៥.៤. កិច្ចសម្រួលពាណិជ្ជកម្ម

វិធានការខាងក្រោម មានគោលបំណងផ្តល់ការគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងកិច្ចសម្រួលពាណិជ្ជកម្ម និងវិហូរពាណិជ្ជកម្មរវាងកម្ពុជានិងប្រទេសដទៃ។ ក្នុងន័យនេះ វិធានការអាទិភាព រួមមាន÷

១). អនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងផែនការកិច្ចសម្រួលពាណិជ្ជកម្មដែលផ្តោតលើការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការផ្តល់សេវាសាធារណៈ។

២). ធ្វើសាមញ្ញកម្មបែបបទនាំចេញ នាំចូល។

## ៥.៥. បរិយាកាសធុរកិច្ចនិងវិនិយោគ

វិធានការខាងក្រោម មានគោលបំណងគាំទ្រការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគសម្រាប់ទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ក៏ដូចជាការបង្កើតឱ្យមានប្រព័ន្ធអេកូឡូស៊ីដែលអំណោយផលដល់

ការរីកចម្រើននៃវិស័យទាំងនេះ ជាពិសេសការតភ្ជាប់ក្នុងខ្សែច្រវាក់តម្លៃតំបន់ និងសកល។ ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងការរៀបចំច្បាប់ និងគោលនយោបាយថ្មីៗដែលមានភាពអំណោយផលដល់វិនិយោគិនដូចជា ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន និងគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញាជាដើម។ ក្នុងន័យនេះ វិធានការអាទិភាព រួមមាន÷

១). អនុវត្តច្បាប់ស្តីពីវិនិយោគនិងច្បាប់សំខាន់ៗដែលមានភាពអំណោយផលដល់វិនិយោគិន។

២). រៀបចំវេទិកាផ្គូផ្គងអ្នកផ្គត់ផ្គង់គ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិកក្នុងស្រុក។

៣). រៀបចំកម្មវិធីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនិងគុណភាពនៃការផ្គត់ផ្គង់គ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិកក្នុងស្រុក។

## ជំពូកទី៦៖ យន្តការស្ថាប័នសម្រាប់ការអនុវត្ត និងការតាមដាននិងវាយតម្លៃ

### ៦.១. ការរៀបចំយន្តការស្ថាប័ន

ការរៀបចំស្ថាប័នដឹកនាំ និងសម្របសម្រួលការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ត្រូវបានធ្វើឡើងក្នុងគោលបំណងលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្រសួងទទួលខុសត្រូវនាំមុខនីមួយៗ ត្រូវមានគណនេយ្យភាពចំពោះការអនុវត្តវិធានការជាក់លាក់ដែលខ្លួនទទួលបន្ទុក។

#### ក. ការសម្របសម្រួលរួម និងការជំរុញការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព

តាមអនុសាសន៍ណែនាំរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គ.ស.ហ.) និងដោយមានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គណៈកម្មាធិការប្រតិបត្តិអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដែលមានសមាសភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រនៃការអនុវត្តផែនការសកម្មភាព ក៏ដូចជាការផ្តល់ទស្សនវិស័យនិងធនធាន ដើម្បីអនុវត្តវិធានការនៃផែនទីបង្ហាញផ្លូវ។ គណៈកម្មាធិការប្រតិបត្តិ ត្រូវដឹកនាំដោយអគ្គលេខាធិការ ក.អ.ក. ដើម្បីទទួលខុសត្រូវ និងតាមដានជាទៀងទាត់លើវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ។ ដោយឡែក គ.ស.ហ. មានតួនាទីជាអ្នកតម្រង់ទិសជាយុទ្ធសាស្ត្រ និងពិនិត្យលើលទ្ធផលនៃការវាយតម្លៃ។

គណៈកម្មាធិការប្រតិបត្តិ ត្រូវមានគណៈកម្មាធិការដោះស្រាយបញ្ហា ជាសេនាធិការ ដោយមានសមាសភាពចូលរួមពីឧត្តមមន្ត្រីបង្គោលមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ហើយមានភារកិច្ចផ្តល់យោបល់បច្ចេកទេសសម្រាប់ដោះស្រាយបញ្ហាប្រឈមសំខាន់ៗដែលមានលក្ខណៈអន្តរវិស័យនិងជាអាទិភាពខ្ពស់ ព្រមទាំងសម្របសម្រួលផ្តល់ការគាំទ្រលើការអនុវត្តវិធានការជាក់លាក់ដែលមានក្រសួងនាំមុខទទួលបន្ទុកអនុវត្ត។

ក្រុមការងារពន្លឿនវិស័យយានយន្ត និងអេឡិចត្រូនិក ដែលដឹកនាំដោយឧត្តមមន្ត្រីមួយរូបរបស់ ក.អ.ក. ត្រូវបានបង្កើតឡើងចំណុះឱ្យគណៈកម្មាធិការទាំងពីរខាងលើ ក្នុងគោលបំណងដឹកនាំនិងរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តវិធានការនីមួយៗ។ ក្រុមការងារនេះ មានសមាសភាពមន្ត្រីបច្ចេកទេសមកពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានតួនាទីដឹកនាំការអនុវត្តវិធានការនីមួយៗ ហើយទទួលខុសត្រូវលើទំនាក់ទំនងជាមួយវិនិយោគិនក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក ដើម្បីឈ្វេងយល់ពីទស្សនៈនិងបញ្ហាប្រឈមដែលតែងតែកើតមានឡើង ក៏ដូចជាផលជះនានាលើការកំណត់អាទិភាពនិងការអនុវត្តផែនការសកម្មភាព។ លើសពីនេះ ក្រុមការងារខាងលើ មានតួនាទីតាមដានវឌ្ឍនភាពជារួមនៃការអនុវត្តផែនការសកម្មភាព។

#### ខ. ការអនុវត្តវិធានការនីមួយៗ

ក្រសួង ស្ថាប័ន ដែលទទួលបន្ទុកនាំមុខក្នុងការអនុវត្តវិធានការនីមួយៗ ត្រូវបង្កើតក្រុមការងារបច្ចេកទេសរៀបចំ និងអនុវត្តវិធានការ ដោយសម្របសម្រួលជាមួយវិស័យឯកជន។ ក្រុមការងារបច្ចេកទេស

នេះ ត្រូវតាមដានវឌ្ឍនភាពនៃវិធានការនីមួយៗដោយផ្ទៀងផ្ទាត់ជាមួយនឹងសូចនាករសមិទ្ធកម្មគន្លឹះ ហើយត្រូវរាយការណ៍រៀងរាល់ ៦ខែម្តង ជូនគណៈកម្មាធិការប្រតិបត្តិ តាមរយៈក្រុមការងារពន្លឿនវិស័យយានយន្ត និងអេឡិចត្រូនិក។ ក្នុងករណីចាំបាច់ ក្រុមការងារបច្ចេកទេសរបស់ក្រសួងទទួលខុសត្រូវនាំមុខ អាចបញ្ចូលសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមផ្តល់យោបល់បច្ចេកទេស និងធានាបាននូវភាពប្រទាក់ក្រឡានៃការអនុវត្តវិធានការក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទាំងនោះ។

រូបភាពទី១០÷ គំនូសបំព្រួញនៃយន្តការស្ថាប័នសម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវ




បន្ទាត់ពេលវេលាខាងក្រោមនេះ បង្ហាញពីថេរវេលានៃការអនុវត្តផែនការសកម្មភាព ដើម្បីជាមគ្គុទ្ទេសក៍តម្រង់ទិសការងារដល់ក្រុមការងារពន្លឿនវិស័យយានយន្ត និងអេឡិចត្រូនិក។ ផែនការសកម្មភាពសម្រាប់វិស័យទាំងពីរនេះ នឹងអនុវត្តស្ទើរតែទាំងស្រុងក្នុងរយៈពេល៣ឆ្នាំ ស្របជាមួយនឹងបន្ទាត់ពេលវេលានៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដើម្បីលើកកម្ពស់ការអភិវឌ្ឍនិងការធ្វើពិពិធកម្មវិស័យឧស្សាហកម្មកម្ពុជា។

រូបភាពទី១១÷ បន្ទាត់ពេលវេលានៃផែនការសកម្មភាពសម្រាប់ការអនុវត្តវិធានការ




## គ. វិធានការត្រូវចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០២២

រាជរដ្ឋាភិបាលកម្ពុជានឹងអនុវត្តវិធានការភាគច្រើនក្នុងឆ្នាំ២០២២ ជាពិសេសវិធានការមួយចំនួនដែលត្រូវចំណាយពេលយូរក្នុងការអនុវត្ត (ឧទាហរណ៍ ការពង្រីកសេវាផ្គូផ្គងការងារ និងការរៀបចំវេទិកាផ្គូផ្គងអ្នកផ្គត់ផ្គង់គ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិកក្នុងស្រុក ជាដើម)។ ក្នុងឆ្នាំ២០២២នេះ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពទៅលើការបង្កើត "ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក" ដើម្បីផ្សារភ្ជាប់កិច្ចសហការរវាងរាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជនក្នុងការអនុវត្តផែនការសកម្មភាពរួមគ្នា។

វិធានការដែលត្រូវចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០២២ រួមមាន÷

*យុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន*

- កំណត់ចក្ខុវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក
- បង្កើត "ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក" ដែលមានសមាសភាពចូលរួមពីស្ថាប័នរដ្ឋ គ្រឹះស្ថាន អ.ប.វ. និងវិស័យឯកជន
- ពង្រឹងការទាក់ទាញវិនិយោគិនដោយបុរេសកម្ម
- កំណត់ទីតាំង ឬតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក។

*ធនធានមនុស្ស និងនវានុវត្តន៍*

- អភិវឌ្ឍកម្មវិធីធ្វើឱ្យប្រសើរនូវជំនាញនៃកម្លាំងពលកម្មសម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក ដោយសហការជាមួយវិស័យឯកជន
- រៀបចំផែនការទាក់ទាញជនបរទេស ទេសន្តប្រវេសន៍ និងអាណិកជនខ្មែរ ដែលមានទេពកោសល្យ

*ហេដ្ឋារចនាសម្ព័ន្ធ*

- អនុវត្តផែនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី
- ពិនិត្យឡើងវិញនូវគោលដៅអត្រាថ្លៃអគ្គិសនី និងស្ថិរភាពនៃការផ្គត់ផ្គង់
- អនុវត្តផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន
- ធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនផ្លូវគោកឆ្លងកាត់ព្រំដែន។

*កិច្ចសម្រួលពាណិជ្ជកម្ម*

- អនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងផែនការកិច្ចសម្រួលពាណិជ្ជកម្មដែលផ្ដោតលើការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការផ្ដល់សេវាសាធារណៈ
- ធ្វើសាមញ្ញកម្មបែបបទនាំចេញ នាំចូល។

*បរិយាកាសធុរកិច្ចនិងវិនិយោគ*

- អនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់សំខាន់ៗដែលមានភាពអំណោយផលដល់វិនិយោគិន
- រៀបចំវេទិកាផ្គូផ្គងអ្នកផ្គត់ផ្គង់គ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិកក្នុងស្រុក
- រៀបចំកម្មវិធីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងគុណភាពនៃការផ្គត់ផ្គង់គ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិកក្នុងស្រុក។

## ឃ. វិធានការដែលតម្រូវឱ្យមានការផ្តល់ធាតុចូល និងការប្តេជ្ញាចិត្តខ្ពស់ពីវិស័យឯកជន

វិធានការទាំងនោះនឹងត្រូវចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០២៣ ឬនៅឆ្នាំបន្តបន្ទាប់ទៀត ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការកំណត់អត្តសញ្ញាណ និងការចូលរួមពីវិស័យឯកជនដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។ វិធានការទាំងនេះ រួមមាន÷

*យុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន*

- បង្កើតយុទ្ធសាស្ត្រប្រទេសប្លូក
- ទាក់ទាញ និងសម្រួលវិនិយោគដល់ក្រុមហ៊ុនឈានមុខ។

*ធនធានមនុស្ស និងនវានុវត្តន៍*

- ធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចការតាមដាន និងវាយតម្លៃនៃគ្រឹះស្ថាន អ.ប.វ.
- ពង្រីក និងពង្រឹងសេវាផ្គត់ផ្គង់ការងារ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន
- ពង្រីកគ្រឹះស្ថាន អ.ប.វ. នៅតាមតំបន់អាទិភាព។

## ៦.២. ការតាមដាន និងវាយតម្លៃ

ដើម្បីធានាថាវិធានការដែលចែងក្នុងផែនទីបង្ហាញផ្លូវ ត្រូវបានអនុវត្តទាន់ពេលវេលា និងផ្តល់ផលជះតាមការរំពឹងទុក រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានលេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ជាសេនាធិការក្នុងការរៀបចំនិងអនុវត្តក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលរួមមាន÷

- **សូចនាករសមិទ្ធកម្មគន្លឹះ** ដែលវាស់វែងផលជះជារួមលើការនាំចេញនិងការបង្កើតការងារក្នុងវិស័យនីមួយៗ ក៏ដូចជាផលជះនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ធនធានមនុស្ស និងបរិយាកាសធុរកិច្ចនិងវិនិយោគ
- **ការកំណត់តួនាទីនិងភារកិច្ចតាមដាន ប្រមូលទិន្នន័យ** រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយមាននីតិវិធី និងរចនាសម្ព័ន្ធច្បាស់លាស់
- **ប្រព័ន្ធរាយការណ៍ជាទៀងទាត់ជូនថ្នាក់ដឹកនាំរាជរដ្ឋាភិបាល** ក្នុងកម្រិតគណៈកម្មាធិការប្រតិបត្តិ និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីវឌ្ឍនភាពនិងបញ្ហាប្រឈមក្នុងការអនុវត្តផែនទីបង្ហាញផ្លូវ÷
    - ការរាយការណ៍អំពីលទ្ធផលតាមដានវឌ្ឍនភាពត្រូវធ្វើឡើងរៀងរាល់ ៦ខែម្តង ជូនគណៈកម្មា-ធិការប្រតិបត្តិ
    - ការរាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃត្រូវធ្វើឡើងរៀងរាល់ ២ឆ្នាំម្តង ជូនកិច្ចប្រជុំ គ.ស.ហ.។

## ជំពូកទី៧៖ សេចក្តីសន្និដ្ឋាន

ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កផលវិបាកយ៉ាងខ្លាំងដល់សេដ្ឋកិច្ចកម្ពុជា ជាពិសេសដល់វិស័យដែលជាចន្ទល់សេដ្ឋកិច្ចមួយចំនួន ដូចជា វិស័យទេសចរណ៍ កាត់ដេរ ផលិតស្បែកជើង និងកាបូប ជាដើម។ ការណ៍នេះទាមទារឱ្យកម្ពុជាពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងវិស័យថ្មីៗដែលមានតម្លៃបន្ថែមខ្ពស់ដូចជា វិស័យយានយន្ត និងអេឡិចត្រូនិក ដែលជាក្បាលម៉ាស៊ីនសម្រាប់អូសទាញកំណើនសេដ្ឋកិច្ច និងបង្កើតឱកាសការងារថ្មីៗបន្ថែម។

នៅក្នុងដំណាក់កាលដ៏មានសារៈសំខាន់នេះ ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា បានកំណត់គន្លងអភិវឌ្ឍន៍ជាក់លាក់ឆ្ពោះទៅការសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងនៃការប្រែក្លាយកម្ពុជាជាមជ្ឈមណ្ឌលផលិតគ្រឿងបង្គុំយានយន្ត និងមជ្ឈមណ្ឌលផលិតបរិក្ខារអេឡិចត្រូនិកដ៏រស់រវើក ព្រមទាំងបានដាក់ចេញនូវផែនការសកម្មភាពដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យទាំងនេះ តាមរយៈការបង្កើនកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងពង្រឹងភាពជាដៃគូជិតស្និទ្ធជាមួយវិស័យឯកជន។

ការអនុវត្តផែនទីបង្ហាញផ្លូវនេះនឹងបង្កើនទំហំនាំចេញក្នុងវិស័យយានយន្តប្រមាណ ៥០០លានដុល្លារអាម៉េរិក និងក្នុងវិស័យអេឡិចត្រូនិកប្រមាណ ១,៦ពាន់លានដុល្លារអាម៉េរិក នៅត្រឹមឆ្នាំ២០២៧ និងបង្កើតការងារថ្មីក្នុងវិស័យយានយន្តប្រមាណ ១០.០០០កន្លែង និងក្នុងវិស័យអេឡិចត្រូនិកប្រមាណ ១៦.០០០កន្លែង នៅត្រឹមឆ្នាំ២០២៧។ តាមការរំពឹងទុក កម្មការិនីនឹងចូលរួមចំណែកប្រមាណ ៥០% ទៅ ៦០% ទៅក្នុងការងារដែលនឹងត្រូវបានបង្កើតសម្រាប់វិស័យទាំងពីរ។

ផែនការសកម្មភាពរួមសម្រាប់ការអភិវឌ្ឍនិងទាក់ទាញវិនិយោគលើវិស័យយានយន្ត និងអេឡិចត្រូនិកនេះ នឹងជំរុញបរិវត្តកម្មក្នុងផ្នែកធនធានមនុស្សនិងនវានុវត្តន៍ ហេដ្ឋារចនាសម្ព័ន្ធ កិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ចនិងវិនិយោគ ដែលនឹងធ្វើឱ្យកម្ពុជាក្លាយជាទីតាំងផលិតកម្មដែលមានភាពទាក់ទាញនិងប្រកួតប្រជែងខ្ពស់ក្នុងផលិតកម្មគ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិក។ តាមរយៈការពង្រឹងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយវិនិយោគិនមកពីជុំវិញពិភពលោក រាជរដ្ឋាភិបាល មានជំនឿយ៉ាងមុតមាំថា អាចនឹងអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក ដែលបង្កើតគុណតម្លៃយ៉ាងសំខាន់សម្រាប់វិនិយោគិន ក៏ដូចជាអាចរុញច្រានកំណើនសេដ្ឋកិច្ច និងផ្តល់ឱកាសការងារកាន់តែប្រសើរថែមទៀតសម្រាប់ប្រជាជនកម្ពុជាផងដែរ។

## ឧបសម្ព័ន្ធទី១÷ អង្គភាពពាក់ព័ន្ធដែលចូលរួមពិគ្រោះយោបល់

ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជាដែលបានចូលរួមរៀបចំ និងអនុវត្តផែនទីបង្ហាញផ្លូវនេះ រួមមាន÷

- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ក្រុមហ៊ុន/ រោងចក្រផលិតយានយន្តនិងអេឡិចត្រូនិកមួយចំនួនដែលកំពុងមានប្រតិបត្តិការនៅកម្ពុជាក៏ដូចជាក្រុមហ៊ុន/ រោងចក្រដែលបានបង្ហាញចំណាប់អារម្មណ៍ក្នុងការបណ្តាក់ទុនវិនិយោគនៅកម្ពុជា ត្រូវបានពិគ្រោះយោបល់ដើម្បីស្វែងយល់ពីចំណុចខ្លាំងនិងបញ្ហាប្រឈមនៃការទាក់ទាញវិនិយោគលើវិស័យយានយន្តនិងអេឡិចត្រូនិកនៅកម្ពុជា។ ការរៀបចំផែនទីបង្ហាញផ្លូវនេះ ក៏បានបញ្ចូលនូវធាតុចូលនិងមតិយោបល់របស់តំណាងវិស័យឯកជន ដែលបានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២២។

## ឧបសម្ព័ន្ធទី២÷ បន្ទាត់ពេលវេលាសម្រាប់អនុវត្តផែនការសកម្មភាព

| វិស័យ | ល.រ | សកម្មភាព | រយៈពេល (២០២២ / ២០២៣ / ២០២៤ / ចាប់ពី២០២៥) |
|---|---|---|---|
| យុទ្ធសាស្ត្រ និងការសម្របសម្រួលអន្តរស្ថាប័ន | ១ | កំណត់ចក្ខុវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព (ក.អ.ក.) | ២០២២–២០២៣ |
| | ២ | បង្កើតក្រុមប្រឹក្សាផ្ដល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក (ក.អ.ក) | ២០២២–២០២៣ |
| | ៣ | ពង្រឹងការទាក់ទាញវិនិយោគិនដោយបុរេសកម្ម (ក.អ.ក.) | ២០២២–២០២៤ |
| | ៤ | កំណត់ទីតាំង/តំបន់សេដ្ឋកិច្ចពិសេសសម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក (ក.អ.ក.) | ២០២២–២០២៤ |
| | ៥ | បង្កើតយុទ្ធសាស្ត្រប្រទេសបូក (Country++ Strategies) (ក.ព.ណ., ក.អ.ក.) | ២០២៣–ចាប់ពី២០២៥ |
| | ៦ | ទាក់ទាញ និងសម្រួលវិនិយោគដល់ក្រុមហ៊ុនឈានមុខ (ក.ស.ហ.វ., ក.អ.ក.) | ២០២៣–ចាប់ពី២០២៥ |
| ធនធានមនុស្ស និងនវានុវត្តន៍ | ៧ | អភិវឌ្ឍកម្មវិធីធ្វើឱ្យប្រសើរនូវជំនាញនៃកម្លាំងពលកម្ម ដោយសហការជាមួយវិស័យឯកជន (ក.ក.ប.) | ២០២២–២០២៤ |
| | ៨ | ធ្វើឱ្យប្រសើរនូវអភិបាលកិច្ចការតាមដាន និងវាយតម្លៃនៃគ្រឹះស្ថាន អ.ប.វ (ក.ក.ប.) | ២០២៣ |
| | ៩ | រៀបចំផែនការទាក់ទាញជនបរទេស ទេសន្តប្រវេសន៍ និងអាណិកជនខ្មែរ ដែលមានទេពកោសល្យ (ក.ឧ.វ.ប.ន.) | ២០២២–២០២៣ |
| | ១០ | ពង្រីក និងពង្រឹងសេវាផ្គូផ្គងការងារ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (ក.ក.ប.) | ២០២៣ |
| | ១១ | ពង្រីកគ្រឹះស្ថាន អ.ប.វ នៅតាមតំបន់អាទិភាព (ក.ក.ប.) | ២០២៣–២០២៤ |
| ហេដ្ឋារចនាសម្ព័ន្ធ | ១២ | អនុវត្តផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី (ក.រ.ថ.) | ២០២២–២០២៤ |
| | ១៣ | ពិនិត្យឡើងវិញនូវគោលដៅអត្រាថ្លៃអគ្គិសនី និងស្ថិរភាពនៃការផ្គត់ផ្គង់ (ក.រ.ថ.) | ២០២២–២០២៣ |
| | ១៤ | អនុវត្តផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ក.ស.ក.) | ២០២២–២០២៤ |
| | ១៥ | ធ្វើសុខដុមនីយកម្មបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនផ្លូវគោកឆ្លងកាត់ព្រំដែន (ក.ស.ក.) | ២០២២–២០២៤ |
| កិច្ចសម្រួលពាណិជ្ជកម្ម | ១៦ | អនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងផែនការកិច្ចសម្រួលពាណិជ្ជកម្ម (ក.ព.ណ.) | ២០២២–ចាប់ពី២០២៥ |
| | ១៧ | ធ្វើសាមញ្ញកម្មបែបបទនាំចេញ នាំចូល (ក.ស.ហ.វ.) | ២០២២–ចាប់ពី២០២៥ |
| បរិយាកាសធុរកិច្ច និងវិនិយោគ | ១៨ | អនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់សំខាន់ៗដែលមានភាពអំណោយផលដល់វិនិយោគិន (ក.អ.ក.) | ២០២២–ចាប់ពី២០២៥ |
| | ១៩ | រៀបចំវេទិកាផ្គូផ្គងអ្នកផ្គត់ផ្គង់គ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិកក្នុងស្រុក (ក.ឧ.វ.ប.ន.) | ២០២២–ចាប់ពី២០២៥ |
| | ២០ | រៀបចំកម្មវិធីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងគុណភាពនៃការផ្គត់ផ្គង់គ្រឿងបង្គុំយានយន្ត និងអេឡិចត្រូនិកក្នុងស្រុក (ក.ឧ.វ.ប.ន.) | ២០២២–ចាប់ពី២០២៥ |

## បរិសិដ្ឋទី៣÷ ផែនការសកម្មភាពសម្រាប់ការអនុវត្តវិធានការ

**វិធានការទី១÷ កំណត់ចក្ខុវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក**

| **ក្រសួង ស្ថាប័នទទួលបន្ទុក÷** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ | **ក្រសួង ស្ថាប័នគាំទ្រ÷** ក្រសួង ស្ថាប័នពាក់ព័ន្ធ។ |
|---|---|

**បរិការណ៍÷**

- វិនិយោគិនមានបំណងស្វែងយល់ពីផែនការរយៈពេលវែង និងការប្តេជ្ញារបស់រាជរដ្ឋាភិបាល សម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក
- រាជរដ្ឋាភិបាលគិតគូរបន្ថែមលើការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក ប៉ុន្តែមិនទាន់មានចក្ខុវិស័យនិងក្របខណ្ឌ ឬគោលការណ៍ណែនាំរួម សម្រាប់ក្រសួង ស្ថាប័នក្នុងការអនុវត្ត។

**វិសាលភាព និងគោលបំណង÷**

១. កំណត់ចក្ខុវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យយានយន្ត និងអេឡិចត្រូនិក ឱ្យស្របជាមួយអាទិភាពរបស់រាជរដ្ឋាភិបាល។

២. បោះពុម្ព និងផ្សព្វផ្សាយផែនទីបង្ហាញផ្លូវដែលមានចែងពីចក្ខុវិស័យ, យុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ជូនអង្គពាក់ព័ន្ធ ជាពិសេសវិស័យឯកជន។

៣. បង្កើតក្រុមការងារពន្លឿនការអនុវត្ត។

| **បង្គោលចរ÷** | **បន្ទាត់ពេលវេលាអនុវត្ត÷** |
|---|---|
| ១. ពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធលើសេចក្តីព្រាងផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា និងសុំការអនុម័តពី គ.ស.ហ.។ | ខែមីនា ដល់ខែវិច្ឆិកា ឆ្នាំ២០២២ |
| ២. បោះពុម្ព និងផ្សព្វផ្សាយផែនទីបង្ហាញផ្លូវនេះដល់វិនិយោគិន និងតួអង្គពាក់ព័ន្ធ។ | ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ខែមីនា ឆ្នាំ២០២៣ |
| ៣. បង្កើតក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ។ | ខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ |

| **វិធានការទី ២÷ បង្កើត "ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក"** | |
|---|---|
| **ក្រសួង ស្ថាប័នទទួលបន្ទុក÷** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ | **ក្រសួង ស្ថាប័នគាំទ្រ÷** ក្រសួង ស្ថាប័នពាក់ព័ន្ធ។ |
| **បរិការណ៍÷**<br>• ការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកនៅមានកម្រិត បានបង្កនូវបញ្ហា "មេមាន់កូនមាន់" ដែលជាបញ្ហាប្រឈមរបស់វិនិយោគិន។ | |
| **វិសាលភាព និងគោលបំណង÷**<br>បង្កើត "ក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក" ដើម្បីជួយជំរុញយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងផែនការសកម្មភាពវិស័យនេះ។ | |
| **បង្គោលចរ÷** | **បន្ទាត់ពេលវេលាអនុវត្ត÷** |
| ១. បញ្ជ្រាបការយល់ដឹងអំពីតួនាទីរបស់ក្រុមប្រឹក្សានេះ និងវិធីសាស្ត្រភាពជាដៃគូ ជូនវិស័យឯកជន ដោយចាប់ផ្តើមពីសហព័ន្ធធុរកិច្ចសំខាន់ៗ និងដៃគូសក្តានុពល។ | ខែឧសភា ដល់ខែកក្កដា ឆ្នាំ២០២២ |
| ២. រៀបចំកិច្ចប្រជុំលើកទី១ នៃក្រុមប្រឹក្សា ពិគ្រោះលើផ្នែកអាទិភាព ដើម្បីកំណត់លទ្ធផលគោលដៅសម្រាប់រយៈពេលខ្លី និងរៀបចំផែនការសកម្មភាពដើម្បីតាមដានលើផ្នែកអាទិភាព។ | ខែមិថុនា ដល់ខែសីហា ឆ្នាំ២០២២ |
| ៣. រៀបចំបទដ្ឋានគតិយុត្តបង្កើតក្រុមប្រឹក្សាដែលចែងពីគោលបំណង សមាសភាព តួនាទី និងភារកិច្ច ដើម្បីជួយជំរុញយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងផែនការសកម្មភាពវិស័យទាំងនេះ។ | ខែកញ្ញា ឆ្នាំ២០២២ ដល់ខែមករា ឆ្នាំ២០២៣ |
| ៤. រៀបចំកិច្ចប្រជុំលើកទី២ នៃក្រុមប្រឹក្សា ដើម្បីផ្សព្វផ្សាយអំពីបទដ្ឋានគតិយុត្តបង្កើតក្រុមប្រឹក្សា និងពិគ្រោះលើរបៀបវារៈអាទិភាពផ្សេងៗ។ | ខែមករា ដល់ខែមីនា ឆ្នាំ២០២៣ |

| វិធានការទី៣÷ ពង្រឹងការទាក់ទាញវិនិយោគិនដោយបុរេសកម្ម | |
|---|---|
| **ក្រសួង ស្ថាប័នទទួលបន្ទុក÷** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ | **ក្រសួង ស្ថាប័នគាំទ្រ÷** ក្រសួងពាណិជ្ជកម្ម។ |
| **បរិការណ៍÷**<br>• ព័ត៌មានមិនសមហេតុផលបានបង្កឱ្យមានការគិតមិនត្រឹមត្រូវចំពោះកម្ពុជា ថាមិនមានទីតាំងអំណោយផលសម្រាប់ផលិតកម្ម<br>• កង្វះការយល់ដឹងពីកាលានុវត្តភាព និងអត្ថប្រយោជន៍ក្នុងការវិនិយោគនៅកម្ពុជា (ឧទាហរណ៍÷ កម្លាំងពលកម្មដែលមានប្រាក់ឈ្នួលប្រកួតប្រជែង, ទីតាំងយុទ្ធសាស្ត្រ)។ | |
| **វិសាលភាព និងគោលបំណង÷**<br>ពង្រីកបណ្ដាញផ្សព្វផ្សាយទៅកាន់វិនិយោគិន និងពង្រឹងសមត្ថភាពដើម្បីបង្កើនការយល់ដឹងរបស់វិនិយោគិនអំពីកាលានុវត្តភាពវិនិយោគនៅកម្ពុជា។ | |
| **បង្គោលចរ÷** | **បន្ទាត់ពេលវេលាអនុវត្ត÷** |
| ១. បញ្ចូលទិន្នន័យពាក់ព័ន្ធនឹងវិនិយោគិន (ឧទាហរណ៍ កំណើននៃការវិនិយោគផ្ទាល់ពីបរទេស, ការធ្វើឱ្យប្រសើរឡើងថ្លៃអគ្គិសនី) ទៅក្នុងការផ្សព្វផ្សាយបែបឌីជីថលសម្រាប់វិនិយោគិនក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក។ | ត្រីមាសទី៤ ឆ្នាំ២០២២ ដល់ត្រីមាសទី១ ឆ្នាំ២០២៣ |
| ២. បើកដំណើរការយុទ្ធនាការវិនិយោគឱ្យកាន់តែទូលំទូលាយតាមរយៈគេហទំព័រ និងផ្សព្វផ្សាយវិស័យយានយន្ត និងអេឡិចត្រូនិក ទៅកាន់បេសកជនការទូតពាក់ព័ន្ធ និងសមាគមធុរកិច្ចនៃប្រទេសគោលដៅ។ | ត្រីមាសទី៤ ឆ្នាំ២០២២ ដល់ត្រីមាសទី១ ឆ្នាំ២០២៣ |
| ៣. បង្កើតវីដេអូផ្សព្វផ្សាយការវិនិយោគដែលបង្ហាញពីការរីកចម្រើននៃវិស័យយានយន្ត និងអេឡិចត្រូនិកនៅប្រទេសកម្ពុជា ដែលមានការតភ្ជាប់ឧស្សាហកម្មទៅនឹងមជ្ឈមណ្ឌលឧស្សាហកម្មក្នុងតំបន់។ | ត្រីមាសទី៤ ឆ្នាំ២០២២ ដល់ត្រីមាសទី១ ឆ្នាំ២០២៣ |
| ៤. រៀបចំសកម្មភាពផ្សព្វផ្សាយការវិនិយោគតាមរយៈសិក្ខាសាលា ដើម្បីទាក់ទាញការវិនិយោគក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក។ | ត្រីមាសទី៤ ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ (អាចនឹងបន្តដល់ឆ្នាំបន្តបន្ទាប់) |

| | |
|---|---|
| ៥. ពង្រឹងយន្តការសម្របសម្រួលការវិនិយោគ ដើម្បីដោះស្រាយការព្រួយបារម្ភនានារបស់វិនិយោគិនក្នុងដំណាក់កាលនីមួយៗនៃការអនុវត្តគម្រោងវិនិយោគរបស់ពួកគាត់។ | ត្រីមាសទី៤ ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ (អាចនឹងបន្តដល់ឆ្នាំបន្តបន្ទាប់) |

**វិធានការទី៤÷ កំណត់ទីតាំង/តំបន់សេដ្ឋកិច្ចពិសេស សម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក**

| | |
|---|---|
| **ក្រសួង ស្ថាប័នទទួលបន្ទុក÷** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ | **ក្រសួង ស្ថាប័នគាំទ្រ÷** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងរ៉ែ និងថាមពល, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងមហាផ្ទៃ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ |

**បរិការណ៍**

- ពុំមានកំណត់ទីតាំង/តំបន់សេដ្ឋកិច្ចពិសេសច្បាស់លាស់សម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក ដែលនាំឱ្យបាត់បង់កាលានុវត្តភាពទាញយកអត្ថប្រយោជន៍ពីការប្រមូលផ្តុំបណ្តាញផលិតកម្ម និងធនធានសម្រាប់ការអភិវឌ្ឍវិស័យទាំងនេះ។

**វិសាលភាព និងគោលបំណង**

១. សហការជាមួយវិស័យឯកជន ដើម្បីកំណត់ទីតាំង/តំបន់សេដ្ឋកិច្ចពិសេសសមស្របមួយឬពីរ សម្រាប់បង្កើតចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក។

២. ផ្សព្វផ្សាយពីទីតាំង/តំបន់សេដ្ឋកិច្ចពិសេស ដែលបានជ្រើសរើសដល់វិនិយោគិនសក្តានុពល។

៣. បង្កើនភាពទាក់ទាញរបស់ទីតាំង/តំបន់សេដ្ឋកិច្ចពិសេស ដែលបានជ្រើសរើសដល់វិនិយោគិនសក្តានុពល។

| **បង្គោលចរ** | **បន្ទាត់ពេលវេលាអនុវត្ត** |
|---|---|
| ១. កំណត់លក្ខណៈវិនិច្ឆ័យដើម្បីជ្រើសរើសតំបន់សេដ្ឋកិច្ចពិសេសដែលសមស្របសម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក។ | ត្រីមាសទី២ ដល់ត្រីមាសទី៣ ឆ្នាំ២០២២ |

| | |
|---|---|
| ២. រៀបចំទស្សនទានបឋមនៃតំបន់សេដ្ឋកិច្ចពិសេសដែលមានសក្តានុពលសម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក។ | ត្រីមាសទី២ ដល់ត្រីមាសទី៣ ឆ្នាំ២០២២ |
| ៣. កំណត់ចន្លោះខ្វះខាតសំខាន់ៗដើម្បីបំពេញ សម្រាប់តំបន់សេដ្ឋកិច្ចពិសេសដែលត្រូវបានជ្រើសរើសក្នុងការប្រកួតប្រជែងនៅក្នុងតំបន់។ | ត្រីមាសទី២ ដល់ត្រីមាសទី៣ ឆ្នាំ២០២២ |
| ៤. កំណត់និងគូសបញ្ជាក់តំបន់សេដ្ឋកិច្ចពិសេស សម្រាប់ចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក។ | ត្រីមាសទី៣ ដល់ត្រីមាសទី៤ ឆ្នាំ២០២២ |
| ៥. បង្កើតវិធានការគោលនយោបាយ ដើម្បីអនុវត្តចង្កោមវិស័យយានយន្ត និងអេឡិចត្រូនិក។ | ត្រីមាសទី៤ ឆ្នាំ២០២២ ដល់ត្រីមាសទី២ ឆ្នាំ២០២៣ |
| ៦. អនុវត្ត និងពិនិត្យវឌ្ឍនភាពនៃវិធានការគោលនយោបាយ។ | ត្រីមាសទី៣ ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤ (អាចនឹងបន្តដល់ឆ្នាំបន្តបន្ទាប់) |

| **វិធានការទី៥÷ បង្កើតយុទ្ធសាស្ត្រប្រទេសបូក** | |
|---|---|
| **ក្រសួង ស្ថាប័នទទួលបន្ទុក÷** ក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ | **ក្រសួង ស្ថាប័នគាំទ្រ÷** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងរ៉ែ និងថាមពល, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ |

**បរិការណ៍**

- យុទ្ធសាស្ត្ររបស់កម្ពុជាក្នុងការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក មិនមានភាពស៊ីចង្វាក់ និងភាពប្រទាក់ក្រឡាជាមួយយុទ្ធសាស្ត្ររបស់ប្រទេសថៃ និងវៀតណាម។
- ការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង អាចជួយដោះស្រាយបញ្ហាប្រឈមមួយចំនួន ដូចជា បញ្ហាភស្តុភារកម្មឆ្លងកាត់ព្រំដែន និងរំហូរកម្លាំងពលកម្ម ជាដើម ហើយក៏អាចជួយកំណត់ភាពស៊ីចង្វាក់ក្នុងការអភិវឌ្ឍវិស័យទាំងនេះ (ឧទាហរណ៍÷ ការរួមគ្នាផ្សព្វផ្សាយដើម្បីទាក់ទាញវិនិយោគិន)។

| **វិសាលភាព និងគោលបំណង**<br>បង្កើតយន្តការកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលថៃ និងវៀតណាម ដើម្បីរៀបចំ និងអនុវត្តវិធានការដោះស្រាយបញ្ហាឆ្លងកាត់ព្រំដែន និងបង្កើនភាពស៊ីចង្វាក់ ក្នុងការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក។ | |
|---|---|
| **បង្គោលចរ** | **បន្ទាត់ពេលវេលាអនុវត្ត** |
| ១. សហការជាមួយវិស័យឯកជនដើម្បីកំណត់ចំណុចអាទិភាពដែលត្រូវធ្វើកិច្ចសហប្រតិបត្តិការ និងបង្កើតយន្តការកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃប្រទេសជិតខាង។ | ត្រីមាសទី៣ ដល់ ត្រីមាសទី៤ ឆ្នាំ២០២៣ |
| ២. ចាប់ផ្តើមកិច្ចសហការ និងចុះអនុស្សារណៈយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង។ | ត្រីមាសទី១ ដល់ត្រីមាសទី៤ ឆ្នាំ២០២៤ |
| ៣. អនុវត្តវិធានការសហប្រតិបត្តិការ។ | ត្រីមាសទី៤ ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥ (អាចនឹងបន្តដល់ឆ្នាំបន្តបន្ទាប់) |

**វិធានការទី៦÷ ទាក់ទាញ និងសម្រួលវិនិយោគដល់ក្រុមហ៊ុនឈានមុខ**

**ក្រសួង ស្ថាប័នទទួលបន្ទុក÷** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**បរិការណ៍**

- ការវិនិយោគពីក្រុមហ៊ុនធំៗក្នុងអនុវិស័យគោលដៅ (ឧទាហរណ៍÷ ក្រុមហ៊ុន Lear ផលិតកៅអី, ក្រុមហ៊ុន Bosch ផលិតគ្រឿងបង្គុំអេឡិចត្រូនិកសម្រាប់យានយន្ត) នឹងផ្តល់ជាករណីសាកល្បងសម្រាប់ការទាក់ទាញវិនិយោគិនដទៃទៀត
- ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនដែលមិនទាន់មានវត្តមាននៅកម្ពុជា អាចនឹងមានការស្ទាក់ស្ទើរមកបណ្តាក់ទុនវិនិយោគ ដោយសារតែអាចនឹងត្រូវចំណាយមូលធនច្រើន និងប្រឈមនឹងហានិភ័យខ្ពស់។

**វិសាលភាព និងគោលបំណង**

បង្កើតយន្តការទាក់ទាញ និងសម្រួលវិនិយោគដល់ក្រុមហ៊ុនឈានមុខ ដើម្បីលើកទឹកចិត្តការវិនិយោគបង្កើតរោងចក្រថ្មីៗនៅកម្ពុជា។

| បង្គោលចរ | ពេលវេលាអនុវត្ត |
|---|---|
| ១. រៀបចំការសិក្សា ដើម្បីស្វែងយល់ពីតម្រូវការសំខាន់ៗ, បញ្ហាប្រឈម និងហានិភ័យចម្បងដែលក្រុមហ៊ុនឈានមុខជួបប្រទះក្នុងការវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍របស់បណ្តាប្រទេសដទៃ។ | ត្រីមាសទី១ ដល់ត្រីមាសទី៤ ឆ្នាំ២០២៣ |
| ២. ពិចារណាក្នុងការដាក់ចេញវិធានការ ដែលផ្តល់ការគាំទ្រជាក់លាក់ ដល់ការវិនិយោគរបស់ក្រុមហ៊ុនឈានមុខ ដោយឆ្លើយតបទៅនឹងលទ្ធផលនៃការសិក្សាខាងលើ។ | ត្រីមាសទី៤ ឆ្នាំ២០២៣ ដល់ត្រីមាសទី២ ឆ្នាំ២០២៤ |
| ៣. ផ្សព្វផ្សាយវិធានការជាក់លាក់ទាំងនេះជាប្រចាំ ទៅកាន់ក្រុមហ៊ុនឈានមុខដោយផ្ទាល់។ | ត្រីមាសទី២ ឆ្នាំ២០២៤ ដល់ត្រីមាសទី៤ ឆ្នាំ២០២៥ |

| **វិធានការទី៧÷ អភិវឌ្ឍកម្មវិធីធ្វើឱ្យប្រសើរនូវជំនាញនៃកម្លាំងពលកម្មសម្រាប់វិស័យយានយន្ត និងអេឡិចត្រូនិក ដោយសហការជាមួយវិស័យឯកជន** | |
|---|---|
